**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université royale de Droit et des Sciences économique

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ចំណាត់ការលើរឿងក្ដីព្រហ្មទណ្ឌរបស់ អង្គការអយ្យការអមសាលាដំបូង

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ផល តារាឧត្តម**

**លី គីមឆាយ**

សាស្ត្រាចារ្យណែនាំ

លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២ និស្សិតអាហារូបករណ៍

ឆ្នាំចូលរៀន ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# លិខិតថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ផល តារាឧត្តម** និងឈ្មោះ **លី គីមឆាយ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់២២ ឆ្នាំសិក្សា ២០១៣-២០១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណជាអនេកប្បការចំពោះ

**លោកឪពុកអ្នកម្តាយ** ដែលលោកទាំងពីរមានគុណដ៏ឧដ្តុងឧត្តមជាទីបំផុតចំពោះកូនៗ ដែលលោកបានផ្តល់កំណើតដល់រូបយើងខ្ញុំ ហើយបានខិតខំលះបង់កម្លាំងញើសឈាមក្នុងការចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងរបស់រូបកូនៗ ទាំងស្មារតី និងសម្ភារៈជាពន់ពេក។ លើសពីនេះទៅទៀត លោកទាំងពីរបានអប់រំទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា ដ៏ល្អប្រពៃពេញមួយជីវិតស្ទើរតែក្លាយជាមហាសមុទ្រដែលរូបយើងខ្ញុំជាកូនៗ មិនអាចហែលឆ្លងបានឡើយ។ លោកទាំងពីរបានលះបង់ទ្រព្យធនទាំងឡាយដែលលោកទាំងពីរបានខិតខំស្វែងរកក្រោមកម្តៅព្រះអាទិត្យសម្រាប់ធ្វើការឧបត្ថម្ភ និងលើកទឹកចិត្តមកលើរូបយើងខ្ញុំចំពោះការសិក្សាអស់រយៈពេល១៦ឆ្នាំ ចាប់តាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់ឧត្តមសិក្សាប្រកបដោយភាពជោគជ័យត្រចះត្រចង់ដូចនេះ និងដើម្បីឱ្យរូបយើងខ្ញុំបានក្លាយបញ្ញាវន្តមួយរូបដែលមានវិជ្ជាជីវៈ និងចំណេះជំនាញមួយច្បាស់លាស់ប្រកបដោយសីលធម៌ គុណធម៌ និងសច្ចធម៌សម្រាប់សង្គម។ ស្របពេលជាមួយគ្នានេះដែរ យើងខ្ញុំជាកូនៗ សូមធ្វើការក្រាបលំឱនកាយគោរពនូវមហាករុណាទិគុណដ៏មហិមាទាំងអស់នេះ ដែលបានធ្វើឱ្យរូបយើងខ្ញុំជាកូនៗនេះចងចាំជានិរន្តចំពោះការលះបង់គ្មានទីបញ្ចប់ និងដ៏ធំធេង ដើម្បីជួយជ្រោមជ្រែងជីវិតរបស់ពួកយើងខ្ញុំជាកូនៗ បានទទួលនូវផ្លែផ្កាដែលជាលទ្ធផលដ៏វិសេសវិសាល សម្រាប់ជាទុនក្នុងការប្រកបរបរចិញ្ចឹមជីវិត ដ៏ដូចជា ជាសកម្មភាពយ៉ាងសកម្មសម្រាប់ជួយអភិវឌ្ឍប្រទេសជាតិ ឱ្យស្របទៅតាមកាលានុវត្តភាពនៃទិដ្ឋភាពសង្គមផងដែរ។

លោកនាយក នាយករង លោកគ្រូ អ្នកគ្រូ នៃសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ទាំងអស់ដែលបានបង្ហាត់បង្រៀន និងផ្ដល់នូវចំណេះដឹងជាមូលដ្ឋានគ្រឹះ សម្រាប់រូបយើងខ្ញុំជាសិស្សក្រេបយកចំណេះវិជ្ជា ដែលជាមាគ៌ាឱ្យរូបយើងខ្ញុំបានសម្រេចបន្តឆ្ពោះមកកាន់សាកលវិទ្យាល័យ។

**ឯកឧត្តម សាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រចារ្យ លោកគ្រូ អ្នកគ្រូ ព្រមទាំងបុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សា នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងកិច្ចការដឹកនាំ គ្រប់គ្រង ជាពិសេសគឺបង្ហាត់បង្រៀន ដើម្បីផ្ដល់ចំណេះដឹងដែលជាទ្រព្យធនដ៏គាប់ប្រសើរ និងមានតម្លៃឥតគណនាសម្រាប់និស្សិតគ្រប់ៗរូប ទទួលបាននូវវិជ្ជាជីវៈផ្នែកច្បាប់បានច្បាស់លាស់ ដើម្បីជម្រុញឱ្យព្រះរាជាណាចក្រកម្ពុជាបានឈានទៅរកនីតិរដ្ឋមួយដ៏រឹងមាំសម្រាប់ប្រជាពលរដ្ឋ។

ជាពិសេស ស្នាដៃមួយដ៏ស្រឡាងនេះ បានលេចចេញជារូបរាងបានឡើង ដោយសារតែមានជួយជ្រោមជ្រែងពីលោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកបានខិតខំបង្ហាត់បង្រៀន ជួយផ្ដល់ដំបូន្មានល្អ ព្រមទាំងជួយទំនុកបម្រុងក្នុងការស្រាវជ្រាវឯកសារផ្សេងៗ ដែលរួមមានទាំងមូលដ្ឋាននៃក្រមព្រហ្មទណ្ឌ ទាំងវិធីសាស្ត្រល្អបន្ថែមទៀត ដើម្បីយកមកធ្វើការចងក្រងជាសារណាបញ្ចប់ការសិក្សារបស់រូបយើងខ្ញុំយកមកប្រគល់ជូនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋ-កិច្ចធ្វើការវាយតម្លៃនូវចំណេះដឹងរបស់រូប យើងខ្ញុំបាទដែលបានសិក្សាអស់រយៈបួនឆ្នាំកន្លងមកនេះ។

លោក លោកស្រីបណ្ណារក្ស រាមច្បងនិស្សិតថ្នាក់នីតិសាស្ត្រ និងមិត្តរួមថ្នាក់ទាំងអស់ដែលបានជួយផ្ដល់ជាមតិយោបល់ និងឯកសារដែលទាក់ទងទៅនឹងប្រធានបទនេះ សម្រាប់ជាទុនក្នុងការធ្វើសារណានេះ ដើម្បីបន្សល់ទុកជាឯកសារបន្តសម្រាប់មិត្តនិស្សិតជំនាន់ក្រោយ។

ជាទីបញ្ចប់យើងខ្ញុំទាំងអស់សូមធ្វើការខន្តីអភ័យទោសនូវរាល់ចំនុចអវិជ្ជមាន រួមមានពាក្យពេចន៍ អក្ខរាវិរុទ្ធដែលកើតមានឡើងដោយកំហុសអចេតនា ស្របពេលជាមួយគ្នានេះយើងខ្ញុំសូមបួងសួង ដល់វត្ថុស័ក្ខសិទ្ធទាំងអស់នៅក្នុងលោក ព្រមទាំងទេវតាទាំងប្រាំបីទិស ប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការកើតមានដល់ចំពោះលោកអ្នកដែលគុណាទាំងអស់ប្រកបដោយសេចក្តី និងសម្រេចនូវរាល់បំណងប្រាថ្នាទាំងពួង។

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសដែលមានការគ្រប់គ្រងដោយរាជរដ្ឋាភិបាល ដែលមានការបែងចែកអំណាចទាំង៣ជា នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការឱ្យមានភាពឯករាជ្យពីគ្នា និងមិនឱ្យមានការអំណាចណាមួយរំលោភបំពានណាមួយឡើយ។ អំណាចតុលាការ គឺជាអំណាចមួយដែលជាអំណាចឯករាជ្យក្នុង ការសម្រេចធ្វើការស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនទាំងឡាយដែលក្នុងនោះច្បាប់ ក៏ជាមូលដ្ឋានមួយដ៏ចំបងសម្រាប់ធ្វើការបកស្រាយបានថាតើប្រទេសមួយជានីតិរដ្ឋដែរឬទេ? ប្រសិនបើប្រទេសមួយមានច្បាប់សម្រាប់ដឹកនាំប្រទេសជាតិនោះ បានសេចក្តីថាប្រជាជនគ្រប់រូបចាំបាច់ត្រូវអនុវត្តតាមច្បាប់ជាដាច់ខាត និងប្រើប្រាស់សិទ្ធិរបស់ខ្លួនដោយមានកម្រិត។ ក្រមសំខាន់ៗទាំង ៤ សម្រាប់អនុវត្តប្រចាំថ្ងៃរួមមាន៖ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាវិធានសម្រាប់បង្ហាញពីសច្ចភាពរបស់ប្រជាពលរដ្ឋកម្ពុជា និងជាយន្តការដ៏សំខាន់មួយសម្រាប់សបញ្ជាក់ឱ្យឃើញពីការអភិវឌ្ឍន៍របស់ប្រទេសជាតិ។ ដើម្បីធ្វើឱ្យវិស័យយុត្តិធម៌មានការប្រសើរឡើង រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់លើប្រព័ន្ធនីតិកម្ម ដោយតាមទិដ្ឋភាពជាក់ស្តែងមានការបង្កើតនៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីសម្តែងឱ្យឃើញពីអត្ថិភាពនៃបទល្មើសរបស់ជនត្រូវចោទ។

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ចែកចេញជា១១ គន្ថី ដែលក្នុងនោះនៅក្នុងគន្ថីទី២ បានធ្វើការចែងអំពីអង្គអយ្យការដែលជាអាជ្ញាធរក្នុងការទទួលបន្ទុកចោទប្រកាន់ បើកការស៊ើបសួរ និងស៊ើបអង្កេត ព្រមទាំងមានមាត្រាជាច្រើនទៀតនៅក្នុងគន្ថីផ្សេងៗដែលមានការបកស្រាយពីដំណាក់កាលជាច្រើននៅក្នុងបណ្តាគន្ថីនីមួយៗ។ អង្គការអយ្យការបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណាក់កាលចោទប្រកាន់ និងធ្វើការបើកការស៊ើបសួរទៅតាមនីតិវិធីព្រហ្មទណ្ឌដើម្បីស្វែងរកភាពពិតនៃរឿងក្តីព្រហ្មទណ្ឌ។

«**តួនាទី និងភារកិច្ចរបស់អង្គការអយ្យការ**» គឺជាចំណងជើងប្រធានបទនៃសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រដែលយើងខ្ញុំទាំងពីរនាក់ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបានសម្រេចធ្វើការជ្រើសរើសដើម្បីធ្វើការបកស្រាយឱ្យបានក្បោះក្បាយ។ តើអង្គការអយ្យការ បានផ្តល់នូវសារៈប្រយោជន៍អ្វីខ្លះសម្រាប់សង្គមជាតិហើយអង្គការអយ្យការបានបំពេញតួនាទី និងភារកិច្ចអ្វីខ្លះស្របតាមនីតិវិធីច្បាប់។ ដោយផ្អែកតាមសារណាមួយនេះយើងនឹងធ្វើការបកស្រាយ ពន្យល់អំពីបញ្ហាមួយចំនួនដែលប្រជាពលរដ្ឋមានភាពមិនច្បាស់លាស់ក្នុងការអនុវត្តនីតិវិធី ដើម្បីឱ្យពួកគាត់មានយល់ដឹងឱ្យកាន់តែច្បាស់លាស់ពីសកម្មភាពរបស់អង្គការអយ្យការខាងលើ។

យើងខ្ញុំនឹងសង្ឃឹមយ៉ាងមុតមាំថា ប្រធានបទសារណាមួយនេះនឹងអាចផ្តល់នូវសារៈប្រយោជន៍ចំពោះអ្នកច្បាប់ ព្រមទាំងនិស្សិតជំនាន់ក្រោយៗទៀត ក្នុងសម្រួលដល់កិច្ចការស្រាវជ្រាវនិងការបំពេញចំនេះដឹងបន្ថែមរបស់និស្សិតគ្រប់ៗរូប។ យើងខ្ញុំក៏សូមធ្វើការសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោកបណ្ឌិត សាស្ត្រចារ្យ ព្រមទាំងរាមច្បងនិស្សិតបានជួយជម្រុញសារណារបស់យើងខ្ញុំឱ្យបានតែប្រសើរ ក្នុងគោលបំណងរួមចំណែកក្នុងការសិក្សាស្រាវជ្រាវរបស់និស្សិត ព្រមទាំងសាធារណជនចែកជាចំណេះដឹងសម្រាប់កសាងប្រទេសជាតិឱ្យមានការអភិវឌ្ឍក្នុងលទ្ធិប្រជាធិបតេយ្យ និងក្លាយជានីតិរដ្ឋមួយដ៏ពិតជាក់ស្តែង។

តែមុននឹងធ្វើការសិក្សាបកស្រាយលើប្រធានខាងលើ យើងខ្ញុំទាំងពីនាក់សូមធ្វើការខន្តីអភ័យទោសពីសំណាក់លោកសាស្ត្រាចារ្យ លោក/លោកស្រី មិត្តអ្នកអាន ព្រមទាំងអ្នកសិក្សាទាំងឡាយ ក្នុងករណីដែលយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវទៅមានភាពចន្លោះប្រហោងណាមួយ សូមមេត្តាជួយបំពេញបន្ថែមនៅចំនុចអវិជ្ជមានទាំងនោះផង។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១. សញ្ញាណទូទៅនៃអង្គការអយ្យការ** ........................................................ ៤

**១.១. រចនាសម្ព័ន្ធរបស់អង្គការអយ្យការ** ........................................................ ៤

១.១.១ អង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត ........................................................ ៥

១.១.២. អង្គការមហាអយ្យការ ........................................................ ៥

**១.២. សមត្ថកិច្ច ភារកិច្ច សិទ្ធិអំណាច និងតួនាទីរបស់អង្គការអយ្យការ** ........................................................ ៧

១.២.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ........................................................ ៧

១.២.២. ភារកិច្ចរបស់ព្រះរាជអាជ្ញា ........................................................ ៧

១.២.៣. សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា ........................................................ ៨

១.២.៤. តួនាទីរបស់ព្រះរាជអាជ្ញា ........................................................ ៩

**១.៣. គោលការណ៍សំខាន់របស់អង្គការអយ្យការ** ........................................................ ១០

១.៣.១. គោលការណ៍អវិភាគ ........................................................ ១០

១.៣.២. គោលការណ៍ឯកភាព ........................................................ ១១

១.៣.៣. គោលការណ៍ឯករាជ្យ ........................................................ ១១

១.៣.៤. គោលការណ៍មិនអាចប្ដឹងជិតចិត្ត ........................................................ ១២

១.៣.៥. គោលការណ៍នៃការមិនទទួលខុសត្រូវ ........................................................ ១២

**ជំពូកទី ២. ការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការ** ........................................ ១៤

**២.១. សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ** ........................................ ១៤

២.១.១. អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ ........................................ ១៤

២.១.២. អាជ្ញាធរទទួលបន្ទុកក្នុងការតម្កល់រឿងទុកឥតចាត់ការ ........................................ ១៥

**២.២. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ** ........................................ ១៥

២.២.១. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើមិនមែនជាបទល្មើស ........................................ ១៥

២.២.២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើស ........................................ ១៧

**២.៣. នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ** ........................................ ២៣

២.៣.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ ........................................ ២៣

២.៣.២. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ ........................................ ២៤

**២.៤. យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ** ........................................ ២៥

**ជំពូកទី ៣ ការចោទប្រកាន់របស់អង្គការអយ្យការ** ........................................ ២៨

**៣.១. ការចោទប្រកាន់តាមការបើកការស៊ើបសួរ** ........................................ ២៨

៣.១.១. លក្ខខណ្ឌ និងទម្រង់ដែលធ្វើឱ្យមានការចំណាត់ការក្នុងការបើកការស៊ើបសួរ ........ ២៩

៣.១.២. នីតិវិធី និងទម្រង់នៃការបើកការស៊ើបសួរ ........................................ ៣១

៣.១.៣. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........................................ ៣៤

**៣.២. ការចោទប្រកាន់តាមការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់** ........................................ ៣៥

៣.២.១. លក្ខខណ្ឌដែលនាំឱ្យមានការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ........................................ ៣៦

៣.២.២. នីតិវិធី និងទម្រង់នៃដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់........................................ ៣៨

៣.២.៣. លក្ខខណ្ឌដែលនាំឱ្យមានសុពលភាពលើដីកាកោះហៅជំនុំជម្រះផ្ទាល់........................................ ៣៩

៣.២.៤. អានុភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ........................................ ៤០

**៣.៣. ចោទប្រកាន់តាមរយៈកំណត់ហេតុបង្ហាញខ្លួនភ្លាម** ........................................ ៤១

៣.៣.១. លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម........................................ ៤១

៣.៣.២. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម........................................ ៤២

៣.៣.៣. អានុភាពនៃការបង្ហាញខ្លួនភ្លាម ........................................ ៤៤

**សេចក្តីសន្និដ្ឋាន** ........................................ ៤៦

**អនុសាសន៍** ........................................ ៤៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ចាប់តាំងពីទទួលបានឯករាជ្យពេញលេញពីសាធារណរដ្ឋបារាំង ព្រះរាជាណាចក្រកម្ពុជាត្រូវបានទទួលស្គាល់ថាជាប្រទេសមួយដែលមានឯករាជ្យភាព និងបូរណភាពទឹកដីយ៉ាងពិតប្រាកដ។ ស្របពេលជាមួយគ្នាផងច្បាប់ក្នុងការដឹកនាំប្រទេស និងរក្សាសណ្តាប់ធ្នាប់របៀបរៀបរយក្នុងសង្គមក៏ត្រូវបានគេឃើញថាប្រជាពលរដ្ឋមានការអនុវត្តយ៉ាងតឹងរឹងផងដែរ ដែលធ្វើឱ្យប្រទេសកម្ពុជានាសម័យនោះក្លាយជាប្រទេស ដែលមានការអភិវឌ្ឍជឿនលឿនជាបណ្តាប្រទេសជិតខាងដែលមានព្រំប្រទល់ជាប់ប្រទេសកម្ពុជា តែសម័យកាលដ៏រុងរឿងនេះមិនបានស្ថិតស្ថេរយូរអង្វែងនោះទេចាប់តាំងមានចលនារដ្ឋប្រហាររបស់សេនាប្រមុខលន់ នល់ ឆ្នាំ ១៩៧២ ប្រទេសកម្ពុជាបានចាប់ផ្តើមធ្លាក់ក្នុងសង្គ្រាមស៊ីវិលជាង ៣ ទសវត្សន៍ រហូតដល់ឆ្នាំ ១៩៩៣ ក្រោមការចរចារក្នុងសន្ធិសញ្ញាទីក្រុងប៉ារីសទើបព្រះរាជាណាចក្រកម្ពុជាទទួលបានសុខសន្តិភាពពិតប្រាកដ។

ក្នុងរយៈពេលជាង ៣ ទស្សវត្សន៍នេះ ព្រះរាជាណាចក្រកម្ពុជាបានឆ្លងកាត់ ៥ សម័យកាលមកក្រោមរូបភាពនៃសង្គ្រាមក្នុងស្រុកនេះ បានធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងរដ្ឋមានការប្រែប្រួលទៅតាមសម័យកាលដែលបានធ្វើឱ្យប្រព័ន្ធច្បាប់សំខាន់ៗ លែងមានអានុភាពក្នុងការគ្រប់គ្រងប្រទេសឱ្យប្រសិទ្ធភាព និងប្រសិទ្ធផល។ នាឆ្នាំ ១៩៩៣ សន្ធិសញ្ញាទីក្រុងប៉ារីស បានធ្វើឱ្យប្រទេសកម្ពុជាចាប់ផ្តើមកកើតរដ្ឋក្លាយជាព្រះរាជាណាចក្រកម្ពុជាទី២ រហូតដល់សព្វថ្ងៃនេះ។ ដើម្បីបង្ការមិនឱ្យមានភាពចលាចលក្នុងស្រុកម្តងទៀត និងរក្សាសណ្តាប់របៀបរៀបរយក្នុងសង្គម រាជរដ្ឋាភិបាលបានផ្តួចផ្តើមធ្វើការបង្កើតច្បាប់សំខាន់ៗ សម្រាប់គ្រប់គ្រងរដ្ឋ ប៉ុន្តែទោះបីជាមានច្បាប់សម្រាប់គ្រប់គ្រងក៏ពិតមែននាសម័យនោះក៏មិនអាចគ្រប់គ្រងស្ថានភាពសង្គម ដែលមានការវិវត្តជារៀងរាល់ថ្ងៃបានដែរ។

ជាតឹកតាងក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាលឆ្នាំ១៩៩៣ ជាក្រមមួយ ពុំបានចែងឱ្យបានលម្អិតអំពីនីតិវិធីក្នុងកិច្ចដំណើររឿងក្តីព្រហ្មទណ្ឌនោះទេ ដែលជាចន្លោះប្រហោងផ្នែកច្បាប់តម្រូវនូវភាពអវិជ្ជមានទាំងនោះ។ ជាក់ស្តែងក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានចូលធរមានថ្ងៃទី១០ ខែ សីហា ឆ្នាំ ២០០៧ មក ច្បាប់ និងបទដ្ឋានគតិយុទ្ធផ្សេងៗទៀត ដែលរួមមានក្រមព្រហ្មទណ្ឌអន្តរកាល និងក្រមនីតិវិធីព្រហ្មទណ្ឌអន្តរកាល ត្រូវបាននិរាករណ៍ដោយច្បាប់ថ្មីនេះ។ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ត្រូវបានចែកចេញជា ១១ គន្ថី និង ៦១២ មាត្រា ដែលគន្ថីនីមួយៗ មានការបែងចែកពីនីតិវីធី តួនាទី ភារកិច្ច របស់បុគ្គលដែលមានសិទ្ធិក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ។ ក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាចំណាត់ការក្នុងការអនុវត្តទៅលើសំណុំរឿងក្តីទាំងឡាយណាដែលជាបទល្មើសព្រហ្មទណ្ឌ ឬអាចនិយាយបានថាក្រមនីតិវិធីព្រហ្មទណ្ឌគឺជាបណ្តុំវិធានទាំងឡាយដែលមានចែងពីតួនាទី ភារកិច្ចរបស់បុគ្គលិក ព្រមទាំងសកម្មភាពរបស់តុលាការព្រហ្មទណ្ឌ ចាប់តាំងនីតិវិធីនៃដំណាក់កាលដំបូងមាន ការសង្ស័យក្នុងការប្រព្រឹត្តបទល្មើសរហូតដល់ផ្តន្ទាទោសតាមផ្លូវច្បាប់ ដែលនេះជាផ្នែកមួយនៃតួនាទី និងភារកិច្ចដ៏សំខាន់របស់អង្គការអយ្យការដែលជាអ្នកចាប់ផ្តើមធ្វើការចោទប្រកាន់លើបទល្មើស។

ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌក្នុងគន្ថីទី២ អង្គការអយ្យការ គឺជាស្ថាប័នឯករាជ្យ ដែលដឹកនាំដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង ព្រមទាំងមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងជាសេនាធិការនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ជួយសម្របសម្រួល និងរក្សាសណ្តាប់ធ្នាប់សាធារណៈផងដែរ។ អង្គការអយ្យការ បានដើរតួនាទីយ៉ាងសំខាន់ទៅរាល់រឿងក្តីទាំងឡាយណាដែលបានទទួលពីជនរងគ្រោះ ឬមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការអនុវត្តនីតិវិធីច្បាប់ដែលតម្រូវឱ្យព្រះរាជអាជ្ញាចាំបាច់ត្រូវគោរពតាម។ ដើម្បីចៀសវាងនូវវិវាទរវាងសិទ្ធិ និងកាតព្វកិច្ចជាមួយនឹងស្ថាប័នផ្សេង ឬវិវាទដែនសមត្ថកិច្ចរបស់ខ្លួន អង្គការអយ្យការក៏បានកំណត់នូវបុគ្គលដែលមានសមាសភាព សិទ្ធិ កាតព្វកិច្ច និងដែនសមត្ថកិច្ចរបស់ខ្លួនជាមួយស្ថាប័នផ្សេងៗ ក៏ដូចជាស្ថាប័នរបស់ខ្លួនផងដែរ។

សំនួរដែលត្រូវលើកយកមកបកស្រាយលើបញ្ហានេះថា តើអង្គការអយ្យការ ឬស្ថាប័នអយ្យការបានតួនាទី និងភារកិច្ចអ្វីខ្លះនៅក្នុងសាលាជម្រះក្តីជាន់ទាប។ តាមរយៈសំនួរដ៏មានន័យនេះ ជាបឋមសារណារបស់យើងខ្ញុំនឹងធ្វើការបកស្រាយឱ្យបានដឹងអំពី **សញ្ញាណទូទៅនៃអង្គការអយ្យការ** ដែលត្រូវបានលើកយកមកធ្វើការបកស្រាយយ៉ាងលម្អិតនៅក្នុង**ជំពូកទី១** ជាមួយគ្នានេះផងដែរយើងនឹងធ្វើការបង្ហាញ **ការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការ** នៅក្នុង **ជំពូកទី២** បន្ទាប់មកគឺ **ការចោទប្រកាន់របស់អង្គការអយ្យការ** មកសិក្សានៅក្នុង**ជំពូកទី ៣** និងជាចុងក្រោយនឹងធ្វើការសរុបសេចក្តីលើប្រធាននៃសារណារបស់ពួកយើងទាំងស្រុង។

# ជំពូកទី១

# សញ្ញាណទូទៅ

# នៃអគ្គការអយ្យការ

# ជំពូកទី១. សញ្ញាណទូទៅនៃអង្គការអយ្យការ

អង្គការអយ្យការ គឺជាស្ថាប័នមួយតំណាងឱ្យអង្គការនីតិប្រតិបត្តិ ដែលនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ហើយមានតួនាទីក្នុងការការពារថែរក្សាសណ្តាប់ធ្នាប់សាធារណៈ។ អង្គការអយ្យការមានតួនាទីធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[1]។ បានសេចក្តីថា អង្គការអយ្យការមានសិទ្ធិក្នុងការបង្ក្រាបរាល់បទល្មើសទាំងឡាយណាដែលជាបទល្មើសព្រហ្មទណ្ឌ ដើម្បីការពារផលប្រយោជន៍សាធារណៈ ក៏ដូចជាផលប្រយោជន៍ជាតិផងដែរ។ អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីការបង្គាប់ឱ្យចាប់ខ្លួន។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន អង្គការអយ្យការ មានសិទ្ធិកេណ្ឌកម្លាំងសាធារណៈដោយផ្ទាល់ជាជំនួយរបស់ខ្លួន ។

អង្គការអយ្យការគឺជាអង្គឯករាជ្យ ដែលមិនស្ថិតក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួននៅអមនោះទេ ហើយសាលាជម្រះក្តីទៀតសោតគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ ក្នុងករណីដែលព្រះរាជអាជ្ញាមានកំហុសឆ្គងក្នុងការបំពេញមុខងារក៏ដោយ ក៏សាលាជម្រះក្តីមិនត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួន យកការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ការហាមឃាត់នេះត្រូវអនុវត្តទាំងក្នុងរឿងព្រហ្មទណ្ឌ ទាំងក្នុងរឿងក្តីផ្សេងទៀត។

## ១.១. រចនាសម្ព័ន្ធរបស់អង្គការអយ្យការ

អង្គការអយ្យការត្រូវបានបែងចែកជាពីរ (២) ប្រភេទគឺ អង្គការអយ្យការ និងអង្គការមហាអយ្យការ៖

[1] មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ១.១.១ អង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត

អង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត គឺជាស្ថាប័នមួយសម្រាប់ធ្វើការចោទប្រកាន់រាល់រឿងក្ដីដែលបានកើតមានឡើងនៅគ្រប់រាជធានី ខេត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អង្គការអយ្យការនេះត្រូវបានដឹកនាំដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងជាតំណាងឱ្យស្ថាប័ននេះ។

#### ក. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា ជាប្រធានក្នុងការដឹកនាំកិច្ចដំណើរការប្រព្រឹត្តទៅរបស់អង្គការអយ្យអមសាលាដំបូងរាជធានី ខេត្ត។ ព្រះរាជអាជ្ញា ជាភាគីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌបានសេចក្ដីថា ព្រះរាជអាជ្ញាជាអ្នកធ្វើការចោទប្រកាន់លើរឿងក្ដីទាំងឡាយណាជារឿងព្រហ្មទណ្ឌ។

#### ខ. ព្រះរាជអាជ្ញារង

ព្រះរាជអាជ្ញារង ជាសេនាធិការស្ថិតក្រោមការដឹកនាំ និងការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តហើយបានប្រើប្រាស់អំណាចទាំងអស់ ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងធ្វើការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ[2]។

### ១.១.២. អង្គការមហាអយ្យការ

អង្គការមហាអយ្យការ គឺជាអង្គការដែលនៅអមសាលាជម្រះក្ដីជាន់ខ្ពស់ ដែលគេហៅថាមហាអយ្យការអមសាលាឧទ្ធរណ៍ និងមហាអយ្យការអមតុលាការកំពូល។ ម្យ៉ាងវិញទៀតអង្គការនេះក៏បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់កិច្ចដំណើររបស់សាលាដំបូងរាជធានីផងដែរ ក្នុងការប្ដឹងឧទ្ធរណ៍ជាដើម។

#### ក. មហាអយ្យការអមសាលាឧទ្ធរណ៍

[2] មាត្រា ៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

មហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវបានដឹកនាំដោយ អគ្គព្រះរាជអាជ្ញា អមដោយអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាក្នុងការជួយសម្រួលដល់កិច្ចដំណើរក្នុងសាលាឧទ្ធរណ៍[3]។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មានអំណាចក្នុងការគ្រប់គ្រងទៅលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញា មានសិទ្ធិអំណាចក្នុងការចាត់តាំងអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាក្នុងកិច្ចដំណើរការផ្សេងៗ និងអង្គជំនុំជម្រះ។ រាល់សេចក្ដីសន្និដ្ឋានដែលបានធ្វើឡើងដោយអគ្គព្រះរាជអាជ្ញារង ឬព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវដាក់ឱ្យអគ្គព្រះរាជអាជ្ញាត្រួតពិនិត្យជាមុនសិនមុនពេលសវនាការ។

អគ្គព្រះរាជអាជ្ញា មានសិទ្ធធ្វើអធិបញ្ញាលើព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់បាន ឬចាត់ឱ្យចោទប្រកាន់ ឬក៏ធ្វើសេចក្ដីសន្និដ្ឋានតាមការយល់ឃើញ[4]។ ម្យ៉ាងវិញទៀត អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិការកិច្ចលើអង្គការអយ្យការទាំងឡាយដែលនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន[5]។ ជាមួយគ្នានេះដែរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឃ្លាំមើលការអនុវត្តច្បាប់ នៅក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ផងដែរ។

## ខ. មហាអយ្យការអមតុលាការកំពូល

អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាតំណាងនៃមហាអយ្យការអមតុលាការកំពូល[6]។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ចូលរួមក្នុងការសុំឱ្យមានការគោរពច្បាប់ នៅពេលដែលមានបណ្ដឹងសារទុក្ខ បណ្ដឹងសើរើ និងបណ្ដឹងតវ៉ាផ្សេងៗទៀតដែលដាក់ជូនតុលាការកំពូលពិនិត្យ។

[3] មាត្រា ៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[4] មាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[5] មាត្រា ៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[6] មាត្រា ៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដើម្បីបញ្ចៀសវិវាទសមត្ថកិច្ចរវាងព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដូច្នេះត្រូវបានកំណត់ពីដែនសមត្ថកិច្ច ភារកិច្ច សិទ្ធអំណាច និងតួនាទីរបស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងឱ្យបានជាក់លាក់។

## ១.២. សមត្ថកិច្ច ភារកិច្ច សិទ្ធិអំណាច និងតួនាទីរបស់អង្គការអយ្យការ

### ១.២.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

ក្នុងករណីដែលមានបទល្មើសមួយកើតមានឡើង តាមការស្រាវជ្រាវលើបទល្មើសមួយអាចនឹងធ្វើឡើងជាច្រើនទីកន្លែងតាមការកំណត់ ដែលពាក់ព័ន្ធនឹងបទល្មើសនោះមានជាអាទ៍ ទីតាំងប្រព្រឹត្តបទល្មើស ទីតាំងជនសង្ស័យរស់នៅ និងទីតាំងចាប់ខ្លួនជនសង្ស័យ។ ដូចនេះហើយ ដើម្បីកំណត់ថាតើបទល្មើសមួយដែលកើតមានឡើង ព្រះរាជអាជ្ញាណាមានសមត្ថកិច្ចក្នុងការដោះស្រាយបទល្មើសនោះ? ចំពោះដែនសមត្ថកិច្ចរបស់ព្រះរាជអាជ្ញាត្រូវបានកំណត់ដូចខាងក្រោមៈ

- ព្រះរាជអាជ្ញានៃទីកន្លែងដែលមានការប្រព្រឹត្តបទល្មើស។
- ព្រះរាជអាជ្ញានៃលំនៅស្ថានរបស់ជនដែលគេសង្ស័យថាបានប្រព្រឹត្តបទល្មើស។
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តបទល្មើស[7]។

### ១.២.២. ភារកិច្ចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា មានភារកិច្ចដើរតួយ៉ាងសំខាន់ជាអ្នកធ្វើការចោទប្រកាន់រាល់បទល្មើសទាំងឡាយណាជាបទល្មើសព្រហ្មទណ្ឌ។ ដោយតួនាទីនេះត្រូវគោរពគោលការណ៍នៃការអនុវត្តការងាររបស់ខ្លួន ដោយមិនលម្អៀង និងលុបបំបាត់ចោលនូវការរើសអើងពូជសាសន៍ ពណ៌សំបុរ ភេទភាសា សាសនា មតិនយោបាយ សញ្ជាតិ និងការរើសអើងផ្សេងៗទៀត[8]។

[7] មាត្រា ៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[8] គោលការណ៍ណែនាំស្តីពី «តួនាទីព្រះរាជអាជ្ញា» អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

ព្រះរាជអាជ្ញាត្រូវទទួលធានាក្នុងការការពារផលប្រយោជន៍ ដោយយកចិត្តទុកដាក់ចំពោះជនសង្ស័យ និងជនរងគ្រោះដោយមិនលម្អៀងព្រមទាំងមានការប្រុងប្រយ័ត្នខ្ពស់ទៅលើគ្រប់ស្ថានភាពដែលមានការពាក់ព័ន្ធទៅនឹងជនសង្ស័យទាំងអស់ ទោះបីជាស្ថានភាពនោះមានប្រយោជន៍ ឬគ្មានប្រយោជន៍សម្រាប់ជនសង្ស័យក៏ដោយ[9]។

ព្រះរាជអាជ្ញាត្រូវរក្សារឿងក្តីដែលមាននៅក្នុងសមត្ថកិច្ចជាការសម្ងាត់ ដើម្បីបញ្ជាក់ពីភាពយុត្តិធម៌នៃតុលាការ។ ម្យ៉ាងវិញទៀត ការពារផលប្រយោជន៍របស់ជនរងគ្រោះ និងត្រូវធានាថាមិនមានការរំលោភអំណាចផ្សេងៗដែលនាំឱ្យជាក្តីបារម្ភរបស់ជនរងគ្រោះ។

### ១.២.៣. សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិអំណាចដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលប្រគល់ឱ្យប្រើប្រាស់តាមការកំណត់។

ព្រះរាជអាជ្ញាមានសិទ្ធិអំណាចជាគោលការណ៍ ក្នុងការទទួលបានគ្រប់ព័ត៌មានទាំងអស់ដែលជាប្រយោជន៍ក្នុងបណ្តឹង។ ក្នុងករណីដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ដោយផ្អែកលើការវិនិច្ឆ័យជា ៣ ទម្រង់គឺ៖ ការបើកការស៊ើបសួរ ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យចូលមកបង្ហាញខ្លួន[10]។

ព្រះរាជអាជ្ញាក្នុងដំណាក់កាលចោទប្រកាន់នេះអាចធ្វើការបែងចែកជា ៣ គឺ អំណាចលើនគរបាលយុត្តិធម៌ អំណាចក្នុងការស៊ើបអង្កេត និងអំណាចក្នុងការចោទប្រកាន់។

- **អំណាចលើមន្ត្រីនគរបាលយុត្តិធម៌[11]៖** ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

[9] គោលការណ៍ណែនាំស្តីពី «តួនាទីព្រះរាជអាជ្ញា» អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

[10] មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[11] មាត្រា ៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ហើយក្នុងករណីដែលមន្ត្រីនគរបាលយុត្តិធម៌មិនបានអនុវត្តដីកាសម្រេចចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ។ ព្រះរាជអាជ្ញាអាចចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស៊ើបអង្កេត និងធ្វើការគ្រប់ការណែនាំដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ជាពិសេសព្រះរាជអាជ្ញាអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ ហើយរៀបចំជំនួសសមាសភាពមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ថ្មី។ ជាមួយគ្នានេះផង ព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ចលើទៅកាន់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីត្រួតពិនិត្យពីកិច្ចដំណើរការលើសំណុំរឿង។

- **អំណាចក្នុងការស៊ើបអង្កេត៖** ដើម្បីធ្វើការចោទប្រកាន់ថាជាបទល្មើសចំពោះអំពើណាមួយនោះព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេត ដោយពិនិត្យលើអង្គហេតុនោះជាបទល្មើសព្រហ្មទណ្ឌដែរឬទេ? និងមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការធ្វើការចោទប្រកាន់ដែរឬទេ? ដោយការស៊ើបអង្កេតនេះព្រះរាជអាជ្ញាមានសិទ្ធិអំណាចក្នុងការបើកស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម មានជាអាទ៍ដូចជា ការឃាត់ខ្លួន ការឆែកឆេរ ការចាប់យកវត្ថុតាង ការស្តាប់ចម្លើយ ការធ្វើកំណត់ហេតុ ការធ្វើកោសល្យវិច័យ និងការស្តាប់ការសន្ទនា។

- **អំណាចក្នុងការធ្វើការចោទប្រកាន់៖** ក្នុងដំណាក់កាលចោទប្រកាន់ ព្រះរាជអាជ្ញាមានសមត្ថកិច្ច និងទទួលបន្ទុកក្នុងការធ្វើចំណាត់ការលើសំណុំរឿង ដោយព្រះរាជអាជ្ញាមានសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ បើទោះបីជាមានបទល្មើសព្រហ្មទណ្ឌក៏ដោយ ឬក៏ធ្វើការចោទប្រកាន់ដែលហៅថា **គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។**

### ១.២.៤. តួនាទីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា បានដើរតួនាទីយ៉ាងសំខាន់ក្នុងចំណាត់ការរឿងក្តីព្រហ្មទណ្ឌ និងស្ថាប័នអយ្យការផងដែរដោយច្បាប់អនុញ្ញាត ឬស្របតាមការអនុវត្តក្នុងស្រុក ដោយធ្វើការស៊ើបអង្កេត

បទល្មើសព្រហ្មទណ្ឌ ពិនិត្យមើលសេចក្ដីសម្រេចរបស់តុលាការ ពិនិត្យមើលនីត្យានុកូលភាពនៃបទល្មើស និងការបំពេញតួនាទីសំខាន់ៗផ្សេងៗទៀតដែលជាប្រយោជន៍របស់សាធារណៈ។

ព្រះរាជអាជ្ញាត្រូវតែបំពេញតួនាទីរបស់ខ្លួនឱ្យបានម៉ឺងម៉ាត់ត្រឹមត្រូវ និងឱ្យទាន់ពេលវេលា ដោយគោរពសេចក្ដីថ្លៃថ្នូររបស់មនុស្ស និងលើកកម្ពស់សិទ្ធិមនុស្សផងដែរ។ ជារួម ព្រះរាជអាជ្ញាត្រូវបានចូលរួមក្នុងកិច្ចដំណើរការដ៏ត្រឹមត្រូវនៃការប្រព្រឹត្តទៅរបស់ប្រព័ន្ធយុត្តិធម៌ លើផ្នែកព្រហ្មទណ្ឌ និងដោយរលូន[12]។

## ១.៣. គោលការណ៍សំខាន់របស់អង្គការអយ្យការ

### ១.៣.១. គោលការណ៍អវិភាគ

គោលការណ៍អវិភាគ បានសេចក្ដីថាគឺជាគោលការណ៍មួយដែលកំណត់ឱ្យព្រះរាជអាជ្ញាមានភារកិច្ចបំពេញក្នុងអង្គការអយ្យការអមសាលាជម្រះក្ដីណាមួយ ត្រូវមានកាតព្វកិច្ចរួមក្នុងមុខងារនោះ និងអាចជំនួសគ្នាទៅវិញទៅមកបានដូចជាក្នុងករណីមានធុរៈ ឬមានជំងឺ ឬអវត្តមានព្រះរាជអាជ្ញាត្រូវបានចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ដើម្បីជំនួសបាន។ តាមគោលការណ៍នេះ តំណាងអយ្យការ អាចបន្តការងារគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមការចាត់តាំងរបស់នាយឋានានុក្រម។

ករណីដែលព្រះរាជអាជ្ញាស្ថិតក្នុងស្ថានភាពមិនអាចបំពេញការងារបាន ឬក្នុងករណីតំណែងព្រះរាជអាជ្ញាស្ថិតក្នុងភាពទំនេរ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់តាំងព្រះរាជអាជ្ញារងណាម្នាក់ឱ្យធ្វើជាព្រះរាជអាជ្ញារងណាម្នាក់ឱ្យធ្វើជាព្រះរាជអាជ្ញាស្ដីទីជំនួសបាន ដើម្បីធានាដំណើរការរបស់អយ្យការអមសាលាដំបូងរហូតដល់មានការតែងតាំងព្រះរាជអាជ្ញាជាផ្លូវការ។

[12] គោលការណ៍ណែនាំស្ដីពី «តួនាទីព្រះរាជអាជ្ញា» អនុម័តដោយសមាជអង្គការសហប្រជាជាតិលើកទី៧ ចាប់ពីថ្ងៃទី២៧ ខែសីហា ដល់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា

### ១.៣.២. គោលការណ៍ឯកតាព

គោលការណ៍នេះ គឺជាគោលការណ៍មួយដែលឱ្យតំណាងអយ្យការទាំងអស់អនុវត្តការងាររបស់ខ្លួនដោយតម្រូវស្ថិតក្រោម ការដឹកនាំ និងការត្រួតពិនិត្យតាមឋានានុក្រមរបស់ខ្លួន។ ឋានានុក្រមនេះ ត្រូវកំណត់ក្នុងមាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧៖

- **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌៖** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាឋានានុក្រមខ្ពស់នៃអង្គការអយ្យការ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃអង្គការអយ្យការអាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់មានដូចជា អង្គការមហាអយ្យការអមតុលាការកំពូល អង្គការមហាអយ្យការអមសាលាឧទ្ធរណ៍ និងអង្គការអយ្យការអមសាលាដំបូង។ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ជាសេនាធិការឱ្យរដ្ឋមន្ត្រីក្រសួងយុត្តធម៌លើកិច្ចការនេះ។
- **អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល៖** អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល គឺជានាយឋានានុក្រមនៃមហាអយ្យការ អមតុលាការកំពូល។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមតុលាការកំពូលត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញា ដែលជានាយឋានានុក្រមរបស់ខ្លួន។
- **អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖** គឺជានាយឋានានុក្រមនៃមហាអយ្យការអមសាលាឧទ្ធរណ៍ ។ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ត្រូវដឹកនាំ និងការទទួលខុសត្រូវរួមរបស់អគ្គព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។ ព្រះរាជអាជ្ញាអមសាលាដំបូង គឺជានាយឋានានុក្រមនៃអយ្យការអមសាលាដំបូង។ ព្រះរាជអាជ្ញារងទាំងអស់នៃអយ្យការអមសាលាដំបូងត្រូវធ្វើការក្រោមការដឹកនាំ និងការទទួលខុសត្រូវរួមរបស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួន។

### ១.៣.៣. គោលការណ៍ឯករាជ្យ

អង្គការអយ្យការ ដែលបង្កើតឡើងអមនៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ គឺមានភាពឯករាជ្យពីអំណាចតុលាការដោយមិនស្ថិតក្រោមអំណាចសាលាជម្រះក្តីដែលខ្លួនបានអមទេ និងជាស្ថាប័ន

ឯករាជ្យមិនចំណុះសាលាជម្រះក្តីទេ។ ពោលគឺតុលាការមិនអាចធ្វើអធិបញ្ញាលើតំណាងអយ្យការទេ ហើយសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់មិនអាចធ្វើការត្រួតពិនិត្យលើកិច្ចដំណើរការ របស់ព្រះរាជអាជ្ញាបានឡើយ ព្រោះវាជាការបំពានគោលការណ៍នៃបែងចែកមុខងារ និងអំណាចរបស់ស្ថាប័នទាំងបី។ ព្រះរាជអាជ្ញាមានសេរីភាព ក្នុងការនិយាយបានដោយសេរីទៅលើអង្គហេតុនៃការសាកសួរដេញដោល ដើម្បីរកភស្តុតាងមកធ្វើការដាក់បន្ទុកក្នុងការចោទប្រកាន់លើជនជាប់ចោទនៅពេលមានសវនាការ។ ក្នុងករណីដែលមានការប្រព្រឹត្តកំហុសឆ្គងកើតឡើងក្នុងពេលបំពេញមុខងាររបស់ព្រះរាជអាជ្ញា សាលាជម្រះក្តីមិនអាចធ្វើការស្តីបន្ទោស ឬសេចក្តីសម្រេចរបស់ខ្លួនទៅលើព្រះរាជអាជ្ញាបានឡើយ។ ដោយសាលាជម្រះក្តីអាចលើកសំណើរទៅកាន់នាយឋានានុក្រមរបស់ព្រះរាជអាជ្ញាដើម្បីធ្វើចំណាត់ការអំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញានេះ។

### ១.៣.៤. គោលការណ៍មិនអាចប្តឹងជំទាស់

អង្គការអយ្យការដែលមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងដែលស្ថិតក្នុងតំណាងអយ្យការអមសាលាដំបូងរាជធានី ខេត្តមិនត្រូវបានពាក់ព័ន្ធទៅការប្តឹងជំទាស់បានទេ ព្រោះថាព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ ហើយព្រះរាជអាជ្ញាមិនតំណាងឱ្យខ្លួនឯងនោះទេ បើទោះបីជាព្រះរាជអាជ្ញាមានការជាប់ពាក់ព័ន្ធនឹងសាច់ញាតិ ឬមានផលប្រយោជន៍ក្នុងបណ្តឹងក៏ដោយ។ ម្យ៉ាងវិញទៀតបើទោះជាមានការចោទប្រកាន់របស់ព្រះរាជអាជ្ញាក៏ដោយមិនមែនបានន័យថាបុគ្គលនោះជាជនត្រូវចោទនោះដែរ។

### ១.៣.៥. គោលការណ៍នៃការមិនទទួលខុសត្រូវ

ព្រះរាជអាជ្ញាក្នុងនាមជាអ្នកតំណាងឱ្យរដ្ឋ ក្នុងការចោទប្រកាន់ចំពោះអង្គហេតុទាំងឡាយណាដែលគិតថាជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីខ្លះ អង្គហេតុដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់អាចនឹងត្រូវច្រានចោលដោយចៅក្រមស៊ើបសួរ នៅក្នុងដំណាក់កាលនៃការស៊ើបសួរ ឬដោយចៅក្រមជំនុំជម្រះ ប្រសិនបើអង្គហេតុនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬមិនមាន

ភស្តុតាងក្នុងការដាក់បន្ទុកគ្រប់គ្រាន់ដើម្បីកំណត់ធាតុផ្សំនៃបទល្មើស។ ប្រសិនបើមានករណីនេះកើតមានឡើង ព្រះរាជអាជ្ញាមិនអាចត្រូវទទួលខុសត្រូវរាល់ការខូតខាតទាំងឡាយដែលកើតចេញពីការសម្រេចចិត្តរបស់ព្រះរាជអាជ្ញាទៅលើរឿងក្តីដែលខ្លួនទទួលខុសត្រូវ ជាពិសេសជនត្រូវចោទ ឬជនជាប់ចោទនៅក្នុងសំណុំរឿងនោះទេ។ ផ្ទុយមកវិញ គោលការណ៍នៃការមិនទទួលខុសត្រូវនៃអង្គការអយ្យការនៅក្នុងការចោទប្រកាន់មិនមែនបានន័យថា ព្រះរាជអាជ្ញាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលដែលខ្លួបានប្រព្រឹត្តកំហុសដែលជាបទល្មើសព្រហ្មទណ្ឌដោយកើតចេញពីឆន្ទៈទុច្ចរិតនៅពេលបំពេញមុខងាររបស់ខ្លួនទេ។ ហេតុនេះ ប្រសិនបើមានករណីដែលព្រះរាជអាជ្ញាបានប្រព្រឹត្តកំហុសដែលជាបទល្មើសព្រហ្មទណ្ឌណាមួយនោះ នាំឱ្យព្រះរាជអាជ្ញាត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌដែលខ្លួនបានប្រព្រឹត្ត។

# ជំពូកទី ២

# ការគម្រូលំរឿងទុកឥតចាត់ការរបស់អគ្គការអេយ្យការ

# ជំពូកទី ២. ការតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការ

## ២.១. សញ្ញាណទូទៅនៃការតម្កល់រឿងទុកឥតចាត់ការ

អង្គការអយ្យការ ជាអ្នកដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា[13]។ មានន័យថា អង្គការអយ្យការជាម្ចាស់នៃបណ្តឹង ដើម្បីធ្វើការចោទប្រកាន់ពីបទល្មើសណាមួយដែលកើតមានឡើងក្រោយពីពេលដែលខ្លួនបានទទួលពាក្យប្តឹង ឬពាក្យបរិហារដោយផ្ទាល់ ឬដោយមន្ត្រីនគរបាលយុត្តធម៌។ តាមរយៈបណ្តឹងដែលទទួលបាន ព្រះរាជអាជ្ញានឹងធ្វើការចោទប្រកាន់ទៅលើអំពើដែលបង្កឱ្យមានព្យសនកម្ម។

ប៉ុន្តែបើតម្រូវឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់នូវរាល់បទល្មើស ដើម្បីយកជនល្មើសមកផ្តន្ទាទោសនោះ ប្រាកដណាស់នឹងកើតមាននូវចំណុចអវិជ្ជាមានច្រើនជាងវិជ្ជាមានសម្រាប់ប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍។ ដោយហេតុថារាល់ការចោទប្រកាន់ហើយមានការផ្តន្ទាទោសដាក់ពន្ធនាគារនាំឱ្យមានតម្រូវការពន្ធនាគារច្រើនសម្រាប់ទទួលបន្ទុករបស់ទណ្ឌិត ជាកត្តាដែលនាំឱ្យធនធានជាច្រើនត្រូវបានខាតបង់ និងនាំប្រទេសទៅជួបនឹងហានិភ័យដែលមិនអាចរំពឹងទុក។

ដូចនេះការចោទប្រកាន់នឹងកើតមាននូវវិបាកពីរ គឺការរក្សាសណ្តាប់ធ្នាប់សាធារណៈឱ្យមានរបៀបរៀបរយល្អ និងការចំណាយធនធានដ៏ខ្ជះខ្ជាយ។ នេះជាហេតុដែលនាំឱ្យព្រះរាជអាជ្ញាមានអំណាចឆន្ទានុសិទ្ធិដោយមិនធ្វើការចោទប្រកាន់ តែតម្កល់រឿងទុកឥតចាត់ការ។ តើអ្វីទៅជាការតម្កល់រឿងទុកឥតចាត់ការ ហើយមូលហេតុយ៉ាងណាទើបនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការ?

### ២.១.១. អត្ថន័យនៃការតម្កល់រឿងទុកឥតចាត់ការ

នៅក្នុងរឿងក្តីព្រហ្មទណ្ឌដែលស្ថិតក្នុងចំណាត់ការរបស់អង្គការអយ្យការ គឺជាដំណាក់កាលមួយក្នុងការចោទប្រកាន់ ព្រោះថាមានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ប៉ុន្តែដោយក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់សេរីភាពដល់ព្រះរាជអាជ្ញាដោយសម្រេចតម្កល់រឿងទុកឥត

[13] មាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ចាត់ការឬ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ[14]។ ដូចនេះនាំឱ្យមានការបកស្រាយថាក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាន់យកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ មានន័យថាទោះបីជាអំពើមួយជាបទល្មើសក៏ដោយ បើពុំមានផលប្រយោជន៍ក្នុងការចោទប្រកាន់នោះទេអាចនាំឱ្យព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកឥតចាត់ការ ដែលនេះខុសពីគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ដែលព្រះរាជអាជ្ញាពុំអាចធ្វើការតម្កល់រឿងទុកឥតចាត់ការនោះឡើយ គឺឱ្យតែមានបទល្មើសព្រហ្មទណ្ឌណាមួយកើតឡើងនោះព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ជាដាច់ខាត។

### ២.១.២. អាជ្ញាធរទទួលបន្ទុកក្នុងការតម្កល់រឿងទុកឥតចាត់ការ

ដូចដែលបានធ្វើការបកស្រាយពីខាងលើ សមាសភាពរបស់ចៅក្រមក្នុងអង្គការអយ្យការអមសាលាដំបូងមានព្រះរាជអាជ្ញា ព្រមទាំងព្រះរាជអាជ្ញារង ដូចនេះអាជ្ញាធរដែលទទួលបន្ទុកក្នុងការតម្កល់រឿងទុកឥតចាត់ការមាន ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង (គោលការណ៍អវិភាគ)។

## ២.២. មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការ

ការតម្កល់រឿងទុកឥតចាត់ការ ជានីតិវិធីមួយដែលមានលក្ខណៈទន់ភ្លន់ដោយហេតុថានីតិវិធីនេះអនុញ្ញាតឱ្យព្រះរាជអាជ្ញាមានសិទ្ធិសម្រេចមិនចោទប្រកាន់បទល្មើសណាមួយដែលខ្លួនយល់ថាមិនគួរចោទប្រកាន់។ ប៉ុន្តែទោះជាយ៉ាងណា ការតម្កល់រឿងទុកឥតចាត់ការត្រូវតែគោរពទៅតាមនីតិវិធី និងមានមូលហេតុគតិយុត្តច្បាស់លាស់។

### ២.២.១. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើមិនមែនជាបទល្មើស

តាមរយៈក្រមព្រហ្មទណ្ឌបានបញ្ញត្តិថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គមគឺជាបទល្មើស[15]។ តាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើសមានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌធរមានប៉ុណ្ណោះ

[14] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[15] មាត្រា ២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន[16]។ មានន័យថាអំពើមួយត្រូវបានចាត់ទុកជាបទល្មើស កាលណាអំពើនោះត្រូវបានបញ្ញត្តិក្នុងច្បាប់ជាធរមាន ក្នុងន័យផ្ទុយត្រលប់មកវិញបើអំពើមួយពុំត្រូវបានបញ្ញត្តិថាជាបទល្មើសទេ អំពើនោះពុំត្រូវបានផ្តន្ទាទោសឡើយ។

មានមូលហេតុពីរដែលជា ហេតុផលដែលនាំឱ្យមានការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលមិនមែនជាបទល្មើសគឺ កង្វះធាតុផ្សំនៃបទល្មើស និងអវត្តមានបទល្មើស។

- **កង្វះធាតុផ្សំនៃបទល្មើស៖** អំពើមួយត្រូវបានចាត់ទុកថាជាបទល្មើសលុះត្រាបានបំពេញធាតុផ្សំបីសំខាន់ៗ បើខ្វះធាតុផ្សំណាមួយចូលរួមនោះត្រូវចាត់ទុកថាគ្មានបទល្មើស ក្នុងនោះរួមមានធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។

  - ធាតុនីត្យានុកូល ឬ ធាតុច្បាប់៖ បានន័យថាអំពើមួយដែលបង្កើតជាព្យសនកម្មដែលបានបង្កការខូចខាតដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ហើយអំពើនោះត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើស នោះជនដែលបានប្រព្រឹត្តអំពើដែលបង្កើតជាព្យសនកម្មត្រូវទទួលទណ្ឌកម្ម ឬការផ្តន្ទាទោសតាមច្បាប់។ ផ្ទុយមកវិញ បើអំពើនោះពុំត្រូវបានបញ្ញត្តិដោយច្បាប់ទេ ជនដែលប្រព្រឹត្តអំពើនោះត្រូវរួចផុតពីការផ្តន្ទាទោស។ ការបកស្រាយខាងលើនេះស្របទៅតាមគោលការណ៍ នីត្យានុកូលភាពនៃបទល្មើស និងទោស[17]។

  - ធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ៖ ជាសកម្មភាពក្នុងការប្រព្រឹត្តអំពើស្តែងចេញមកខាងក្រៅហើយអំពើនោះបានបង្កចេញជាព្យសនកម្មដែលជាទំនាក់ទំនងរវាងហេតុ និងផល អំពើ និងបច្ច័យ។ ប្រសិនបើជនណាមួយគ្រាន់តែមានគំនិត តែពុំបានប្រព្រឹត្តអំពើតាមការគិតរបស់គេនោះទេនឹងគ្មានបទល្មើសកើតឡើងឡើយ។

  - ធាតុអត្តនោម័ត ឬ ធាតុចិត្តសាស្ត្រ៖ ជាផ្នែកខាងក្នុង ឬកិរិយាផ្លូវចិត្តរបស់ជនល្មើសចំពោះអំពើល្មើសដែលខ្លួនបង្កឡើង។ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ច្បាប់បានបញ្ញត្តិថាគ្មាន

[16] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[17] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

បទល្មើសទេ ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតឡើងចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែសឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ[18]។ ទោះបីជនល្មើសពុំមានចេតនាក្នុងការប្រព្រឹត្តក៏ដោយ តែបើអំពើនោះកើតឡើងដោយអចេតនាដោយការជឿជាក់ ឬការធ្វេសប្រហែសនោះក៏ត្រូវទទួលខុសត្រូវចំពោះទង្វើដែលខ្លួនបង្កើតឡើងដែរ។

– **អវត្តមានបទល្មើស៖** រាល់បទល្មើសសុទ្ធតែជាអំពើដែលបង្កឱ្យមានព្យសនកម្ម ប៉ុន្តែរាល់អំពើដែលបង្កឱ្យមានព្យសនកម្មពុំមែនសុទ្ធតែជាបទល្មើសព្រហ្មទណ្ឌនោះឡើយ។ ដូចនេះសំណុំរឿងខ្លះពុំមែនជាបទល្មើសព្រហ្មទណ្ឌឡើយ គឺគ្រាន់តែជាប្រភេទរឿងក្តីរដ្ឋប្បវេណីតែប៉ុណ្ណោះ។

ឧទាហរណ៍៖ ការពុំអនុវត្តកាតព្វកិច្ចសងប្រាក់របស់កូនបំណុលជាអាទិ៍ ហើយម្ចាស់បំណុលបានប្តឹងពីបទឆបោក ឬ រំលោភលើទំនុកចិត្ត។ ដូចនេះតំណាងអយ្យការនឹងសម្រេចតម្កល់រឿងទុកឥតចាត់ការ ។

### ២.២.២. ការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើស

ក្នុងករណីដែលមានបទល្មើសមួយត្រូវបានកើតឡើង មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា (ស្របតាមមាត្រា ១៣១ថ្មី នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣) ប៉ុន្តែស្របតាមកាលៈទេសៈខ្លះចំពោះការប្រព្រឹត្តបទល្មើស ហេតុ និងបច្ច័យនៃបទល្មើសដែលគ្រាន់តែបង្កើតជាព្យសនកម្មតិចតួច ពុំមានផលប្រយោជន៍ក្នុងការចោទប្រកាន់ នោះតំណាងអយ្យការមានឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ឬមិនចោទប្រកាន់ចំពោះអំពើដែលជាបទល្មើសព្រហ្មទណ្ឌបាន (គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់)។

ដូចនេះ យើងអាចធ្វើការបែងចែកមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការចំពោះអំពើដែលជាបទល្មើសជាពីរករណីតាមការសិក្សាទៅលើបទដ្ឋានគតិយុត្តឬ ករណីជាក់ស្តែង ក្នុងនោះរួមមាន មូលហេតុគតិយុត្ត និងការចោទប្រកាន់មិនផ្តល់ប្រយោជន៍។

[18] មាត្រា ៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

– **មូលហេតុគតិយុត្តៈ** ហេតុដែលច្បាប់បានបញ្ញត្តិក្នុងការរារាំងមិនឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់ទោះអំពើនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយ។

- អភ័យឯកសិទ្ធិៈ សិទ្ធិពិសេសដែលច្បាប់បានផ្តល់ឱ្យ ដោយពុំអាចធ្វើការចោទប្រកាន់បានទាំងដែលជនល្មើសបានប្រព្រឹត្តបទល្មើស ។

ឧទាហរណ៍ៈ អំពើលួចទ្រព្យសម្បត្តិរបស់បុព្វញាតិឬ បច្ឆាញាតិឬ សហព័ទ្ធពុំត្រូវទទួលរងនូវការចោទប្រកាន់ឡើយ[19]។

- អនិយ័តភាពនៃកិច្ចនីតិវិធីៈ សំដៅដល់ភាពពុំស្របតាមបញ្ញត្តិច្បាប់នៃការអនុវត្តកិច្ចនីតិវិធីក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងអយ្យការ។

ឧទាហរណ៍ៈ ការចុះឆែកឆេរដោយផ្តើមឡើងមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និង ក្រោមម៉ោង ១៨ (ដប់ប្រាំបី) ល្ងាច[20]។

- ការរលត់នៃបណ្តឹងអាជ្ញា[21]ៈ
    - មរណភាពនៃជនល្មើសៈ ជនល្មើស គឺជាប្រធាននៃបទល្មើសដែលនាំឱ្យមានការបង្កជាព្យសនកម្ម និងកម្រិតគ្រោះថ្នាក់ដល់សង្គមដែលតម្រូវឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់ ហើយសុំឱ្យតុលាការផ្តន្ទាទោសចំពោះអំពើល្មើសនោះ។ ប៉ុន្តែក្នុងករណីដែលជនល្មើសពុំមានវត្តមានជាអចិន្ត្រៃយ៍នៅលើលោកនេះ ហើយតំណាងអយ្យការធ្វើការចោទប្រកាន់ដើម្បីយកមកផ្តន្ទាទោសនោះហាក់ដូចជាពុំចាំបាច់នោះឡើយព្រោះការចោទប្រកាន់ខាងព្រហ្មទណ្ឌ គឺដើម្បីធ្វើការអប់រំជនល្មើសឱ្យមកប្រព្រឹត្តអំពើល្អហើយអាចរស់នៅក្នុងសង្គមសារជាថ្មី ពុំមែនជាការសងសឹកទៅលើទង្វើដែលគេបានធ្វើឡើយ។

[19] មាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[20] មាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[21] មាត្រា ៧ និង មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

○ ការផុតអាជ្ញាយុកាលៈ សំដៅទៅលើកំឡុងពេលជាកំណត់ណាមួយដោយច្បាប់ដែលអាចធ្វើការចោទប្រកាន់បាន។ ប្រសិនបើថិរវេលាដែលបានកំណត់នោះបានកន្លងហួសនោះ ការចោទប្រកាន់របស់តំណាងអយ្យការពុំអាចធ្វើបាននោះទេ។ អាជ្ញាយុកាលនៃបទល្មើស ឬ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌមានជាអាទ៏ៈ

- ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៥ (ប្រាំ) ឆ្នាំ ចំពោះបទមជ្ឈិម
- ១ (មួយ) ឆ្នាំ ចំពោះបទលហុ[22]

ប៉ុន្តែអាជ្ញាយុកាលមិនត្រូវបានផុតរលត់ឡើយចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម[23]។

○ ការលើកលែងទោសជាទូទៅៈ បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជនល្មើសតាមច្បាប់កំណត់។ ប៉ុន្តែទោះជាយ៉ាងនេះក្តីបើពិនិត្យមើលមាត្រា ៩០ថ្មី កថាខណ្ឌទី ៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ បញ្ញត្តិថារដ្ឋសភាអនុម័តច្បាប់ស្តីពី ការលើកលែងទោសជាទូទៅ។ មានន័យថាទោះបីអំពើខ្លះជាបទល្មើសក៏ដោយ តំណាងអយ្យការពុំចាំបាច់ធ្វើការចោទប្រការឬ បញ្ឈប់ការចោទប្រកាន់ ឬ បញ្ឈប់ការអនុវត្តទោស បើរដ្ឋសភាបានអនុម័តច្បាប់ស្តីពី ការលើកលែងទោសជាទូទៅ។

○ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌៈ ជាការលុបចោលនៃច្បាប់ព្រហ្មទណ្ឌលែងឱ្យប្រើ ឬ ការលុបចោលដែលផ្ទុយនឹងច្បាប់ថ្មីដែលកំពុងចូលជាធរមាន។ ការនិរាករណ៍នាំឱ្យអំពើល្មើសពុំត្រូវបានធ្វើការចោទប្រកាន់ដោយបញ្ចប់ការចោទប្រកាន់ឬ ការដែលកំពុងអនុវត្តទោសត្រូវបានបញ្ចប់។

[22] មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[23] មាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

○ អាជ្ញាអស់ជំនុំ៖ គោលការណ៍អាជ្ញាអស់ជំនុំ ឬគោលការណ៍ដែលពុំអាចជម្រះពីរដងលើរឿងក្តីតែមួយ។ ទោះបីជាមានការកំណត់ឈ្មោះបទល្មើសថ្មីក៏ដោយ បើជនល្មើសត្រូវបានតុលាការផ្តន្ទាទោស ឬការលើកលែងទោសជាស្ថាពរនោះពុំអាចធ្វើការចោទប្រកាន់ទេ ដើម្បីមានការធានាសិទ្ធិពលរដ្ឋ និងជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋទៅលើតុលាការ។

○ ការសម្របសម្រួលជាមួយរដ្ឋ៖ ជាគោលការណ៍បណ្តឹងអាជ្ញាពុំអាចអនុញ្ញាតឱ្យមានការបញ្ឈប់តាមតែទំនើងចិត្តបានទេ លើកលែងតែមានការកំណត់ពីច្បាប់ជាពិសេស។ ជាឧទាហរណ៍ចំពោះបទល្មើសដែលជាអំពើហិង្សាប៉ះពាល់ខាងផ្លូវចិត្តឬ ផ្លូវជីវភាពសេដ្ឋកិច្ច និងបទល្មើសមជ្ឈិមស្រាលឬ បទលហុ ការផ្សះផ្សាឬ សម្រុះសម្រួលអាចធ្វើទៅបានតាមការយល់ព្រមពីភាគីទាំងសងខាង[24]។

○ ការដកពាក្យប្តឹង៖ ជនរងគ្រោះអាចធ្វើការដកពាក្យប្តឹង ចំពោះបទល្មើសមួយចំនួនដែលជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ។ លក្ខខណ្ឌនៃការចោទប្រកាន់នោះមានជាអាទិ៍ អំពើហិង្សាក្នុងគ្រួសារដែលសហព័ទ្ធជាជនរងគ្រោះអាចដកពាក្យប្តឹង ហើយតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់បានឡើយ[25]។

○ ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល៖ ករណីនេះគេសង្កេតឃើញភាគច្រើនចំពោះការអនុវត្តលើបទល្មើសចរាចរណ៍ ដោយភាគីជនរងគ្រោះទទួលបានសំណងសមរម្យដោយការបង់ប្រាក់សម្របសម្រួល ហើយខ្លួនដាក់សំណើដើម្បីកុំឱ្យមានការចោទប្រកាន់ណាមួយ ។

- ការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ

○ វិបល្លាសស្មារតី៖ កត្តាដែលនាំឱ្យជនល្មើសពុំអាចយល់ដឹងពីលទ្ធផលនៃអំពើដែលខ្លួនបានប្រព្រឹត្តថាជាបទល្មើស ប៉ុន្តែបញ្ហាស្មារតីដែលនាំឱ្យមានការអោនថយការយល់ដឹងពីទង្វើ

[24] មាត្រា ២៦ នៃច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥
[25] មាត្រា ៣៦ នៃច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

ដែលប្រព្រឹត្តឡើងដោយការសេពគ្រឿងស្រវឹង ការសេពគ្រឿងញៀនជាអាទិ៍ ពុំមែនជាលេសដែលអាចរួចផុតពីការចោទប្រកាន់នោះឡើយ។

- ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរៈ អំពើខ្លះទោះបីជាការប្រព្រឹត្តស្តែងឡើងចេញជាបទល្មើសយ៉ាងណាក្តី តែបើស្ថិតក្នុងការអនុញ្ញាតដោយបទបញ្ញត្តិនានា ឬតាមការបញ្ជារបស់អាជ្ញាធរអំពើនោះត្រូវរួចផុតពីការចោទប្រកាន់។

- ការការពារស្របច្បាប់ៈ ជាកិច្ចការពារជាធម្មានុរូបដើម្បីរួចផុតពីការរំលោភបំពាន។ តែចំណុចនេះមានការកម្រិតនូវលក្ខខណ្ឌជាអាទិ៍។
  - បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬ ការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ
  - បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង
  - គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន[26]។

- សច្ចធារណ៍នៃការការពារស្របច្បាប់ៈ ជាការសន្មតដូចការការពារស្របច្បាប់ក្នុងករណី
  - បទល្មើត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សាឬ ដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។
  - បទល្មើបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬ ការប្លន់ដែលអនុវត្តដោយហិង្សា[27]។

- ស្ថានភាពចាំបាច់ៈ ភាពជាការចាំបាច់ដែលត្រូវតែប្រព្រឹត្តបទល្មើស ដែលមានលក្ខខណ្ឌពីរដូចខាងក្រោមៈ

[26] មាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[27] មាត្រា ៣៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

- បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃឬ ការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង
- គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់[28]។

○ អានុភាពនៃកម្លាំង ឬការបង្ខំ៖ កម្លាំង ឬការបង្ខំ គឺត្រូវតែជាព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សហើយត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន។ ប៉ុន្តែក្នុងករណីដែលបុគ្គលប្រព្រឹត្តបទល្មើសមានគោលបំណងឱ្យកើតមានឡើង នោះវាស្ថិតក្នុងឆន្ទះរបស់ខ្លួន។ ដូចនេះ ប្រសិនបើបុគ្គលណាម្នាក់ដែលបានប្រព្រឹត្តបទល្មើសដោយសារតែស្ថានភាពនៃកម្លាំងឬ ការបង្ខំ ហើយដែលខ្លួនពុំអាចទប់ទល់បាន នោះគេមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

○ អនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំ៖ ចំពោះជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់ពីអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ឬហៅបានថានីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[29]។ ទោះជាយ៉ាងនេះក្តី ពុំមានន័យថាអនីតិជនត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ គឺជាអញ្ញត្រកម្មច្បាប់បានកំណត់ឱ្យមានជាវិធានការអនុវត្តចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅដែលបានប្រព្រឹត្តបទល្មើស ដែលស្ថិតក្រោមវិធានការតាមដានវិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ[30]។

– **ការចោទប្រកាន់មិនផ្តល់ប្រយោជន៍៖** សំដៅចំពោះការចោទប្រកាន់ ដែលតំណាងអយ្យការអាចធ្វើការថ្លឹងថ្លែងពិចារណាទៅលើស្ថានភាពនៃបទល្មើស ចារី ជនរងគ្រោះជាអាទិ៍ ដែលនាំឱ្យមិនធ្វើការចោទប្រកាន់ ដោយហេតុថាការចោទប្រកាន់នឹងពុំមានផ្តល់ផលប្រយោជន៍អ្វីសោះដល់សង្គម និងផ្ទុយពីគោលបំណងនៃបណ្តឹងអាជ្ញា។ តាមការបង្ហាញខាងលើមានមូលហេតុមួយចំនួនដែលជាកត្តានាំឱ្យតំណាងអយ្យការពុំធ្វើការចោទប្រកាន់ក្នុងនោះរួមមាន៖

[28] មាត្រា ៣៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[29] មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
[30] មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

- កត្តាចំណាត់ការៈ ការចោទប្រកាន់ដែលការស៊ើបអង្កេតមិនបានផល ពេលវេលាត្រូវបានអូសបន្លាយជាហូរហែរ។
- កត្តាចារីៈ ការប្រព្រឹត្តបទល្មើសរបស់ចារីក្នុងស្ថានភាពមួយដែលចាំបាច់ពុំអាចគេចផុតបាន ការទទួលស្គាល់នូវកំហុសរបស់ខ្លួន បញ្ហាបន្ទុកក្នុងគ្រួសារជាអាទិ៍។
- កត្តាជនរងគ្រោះៈ ការបោះបង់ពាក្យបណ្តឹង ការមិនអើពើនឹងព្យសនកម្មដែលខ្លួនទទួលរង ការខកខានក្នុងនីតិវីធី។
- កត្តាព្យសនកម្មៈ ការខូចខាតមានលក្ខណៈតិចតួចដែលបានកើតឡើងដោយអំពើល្មើស។

គួរបញ្ជាក់ផងដែរថា ទោះបីតំណាងអយ្យការមានអំណាចឆន្ទានុសិទ្ធិក្នុងការតម្កល់រឿងទុកឥតចាត់ការតាមរយៈក្រមនីតិវិធីក៏ពិតមែន ប៉ុន្តែការសម្រេចតម្កល់រឿងទុកឥតចាត់ការ ត្រូវមានសំអាងច្បាប់និង សំអាងហេតុហើយការតម្កល់រឿងទុកឥតចាត់ការនេះ គ្មានអាជ្ញាអស់ជំនុំទេ[31]។ មានន័យថាថ្វីត្បិតតែមានការតម្កល់រឿងទុកឥតចាត់ការ ក៏មានហេតុផ្សេងដែលនាំឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់សារជាថ្មីបាន ដែលនឹងត្រូវធ្វើការបកស្រាយនៅផ្នែកខាងក្រោម (យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ)។

## ២.៣. នីតិវិធី និងអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

### ២.៣.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

ក្រោយពីទទួលបានពាក្យប្តឹង ឬពាក្យបរិហារដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក តំណាងអយ្យការត្រូវថ្លឹងថ្លែងលើពាក្យប្តឹងនោះ ថាតើរឿងក្តីដែលខ្លួនទទួលនោះបានបំពេញធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ឬ មិនចោទប្រកាន់។ ទោះជាយ៉ាងណាក៏ដោយ ការ

[31] មាត្រា ៤១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សម្រេចតម្កល់រឿងទុកឥតចាត់ការតំណាងអយ្យការត្រូវបើកការស៊ើបអង្កេតបឋមឬ បង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម មុននឹងចេញសេចក្តីសម្រេច[32]។

បន្ទាប់ពីបើកការស៊ើបអង្កេតបឋម ឬ បង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមត្រូវបានបញ្ចប់ ហើយយល់ឃើញថាត្រូវតម្កល់រឿងទុកឥតចាត់ការចំពោះពាក្យប្តឹងឬ ពាក្យបរិហារនោះ តំណាងអយ្យការនឹងចេញដីកាមួយដែលមានឈ្មោះថា ដីកាតម្កល់រឿងទុកឥតចាត់ការ។ ក្រោយពីចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវជូនដំណឹងដល់អ្នកប្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីដែលមានចែងក្នុងមាត្រា ៥០ (បញ្ជីនៃពាក្យប្តឹង)[33]។ ការជូនដំណឹងនេះជាលក្ខខណ្ឌចាំបាច់សម្រាប់ឱ្យអ្នកប្តឹងអាចតវ៉ា ចំពោះការមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ។

### ២.៣.២. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ចំពោះអានុភាពនៃការតម្កល់រឿងទុកឥតចាត់ការត្រូវបានបញ្ញត្តិក្នុងមាត្រា ៤១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលនាំឱ្យគ្មានអាជ្ញាអស់ជំនុំទេ។ តាមគោលការណ៍អាជ្ញាអស់ជំនុំជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែល ទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ[34]។ ដោយហេតុថាតំណាងអយ្យការមានឆន្ទានុសិទ្ធិ តាមការយល់ឃើញរបស់ខ្លួនក្នុងការសម្រេចចោទប្រកាន់ ឬ មិនចោទប្រកាន់ ដូចនេះប្រសិនបើតាមការយល់ឃើញរបស់ខ្លួនដោយធ្វើការតម្កល់រឿងទុកឥតចាត់ការ ហើយមានអានុភាពជាអាជ្ញាអស់ជំនុំចំពោះសេចក្តីសម្រេច នោះពុំមានលក្ខណៈសមហេតុផលឡើយ។

[32] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[33] មាត្រា ៤១ កថាខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[34] មាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ២.៤. យន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ

ដោយហេតុដូចការបកស្រាយខាងលើ ការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំទេ មានន័យថាការចោទប្រកាន់អាចត្រូវបានធ្វើឡើងសារជាថ្មី។ ចំពោះយន្តការប្រឆាំងនឹងការតម្កល់រឿងទុកឥតចាត់ការ ដើម្បីឱ្យធ្វើការចោទប្រកាន់ជាថ្មីមានដូចខាងក្រោម៖

- ការសើរើកែប្រែសេចក្តីសម្រេចរបស់តំណាងអយ្យការ៖ ទោះបីពាក្យប្តឹងត្រូវបានតម្កល់រឿងទុកឥតចាត់ដោយតំណាងអយ្យការក៏ដោយ បើក្រោយមកខ្លួនយល់ឃើញថាអំពើល្មើសមានធាតុផ្សំគ្រប់គ្រាន់ ឬមានភស្តុតាងថ្មីដែលអាចបញ្ជាក់ពីរឿងហេតុ នោះតំណាងអយ្យការអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញបាន លើកលែងតែបណ្តឹងអាជ្ញានោះមិនទាន់រលត់នៅឡើយ[35]។
- ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍៖ កាលណាពាក្យប្តឹងត្រូវបានតម្កល់ទុកឥតចាត់ការហើយអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនោះទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងកំឡុងពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ បើការតវ៉ាមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នឹងចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់[36]។
- ការធ្វើអធិបញ្ញាតាមនាយឋានានុក្រមនៃអង្គការអយ្យការ៖ ដោយអង្គការអយ្យការជាអង្គឯកភាពដែលត្រូវស្ថិតក្រោមការដឹកនាំ និងការត្រួតពិនិត្យតាមនាយឋានានុក្រមរបស់ខ្លួនមានជាអាទិ៍ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[37]។
- ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖ ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈឹម អាចដាក់ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ដែលមានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងក្នុងលក្ខខណ្ឌដែលកំណត់ក្នុងមាត្រា ១៣៩ (ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០ (ការបង់ប្រាក់តម្កល់ទុក) នៃក្រមនីតិវិធីព្រហ្ម

[35] មាត្រា ៤១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[36] មាត្រា ៤១ កថាខណ្ឌទី ៤,៥ និង ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[37] មាត្រា ៧៥ កថាខណ្ឌទី ១ នៃច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា

ទណ្ឌ[38]។ បន្ទាប់មកចៅក្រមស៊ើបសួរនឹងបញ្ជូនបណ្ដឹងនេះទៅព្រះរាជអាជ្ញាដើម្បីឱ្យធ្វើការចោទប្រកាន់ ។

[38] មាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

# ជំពូកទី ៣

# ការចោទប្រកាន់

# របស់អគ្គការអយ្យការ

# ជំពូកទី ៣ ការចោទប្រកាន់របស់អង្គការអយ្យការ

មុននឹងឈានទៅរកការចោទប្រកាន់លើជនណាម្នាក់ទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ លុះត្រាតែមានការទទួលបណ្តឹងទាមទារពីជនរងគ្រោះឬ អ្នកតំណាងរបស់ជនរងគ្រោះឬ ទទួលបានរបាយការណ៍ពីមន្ត្រីនគរបាលយុត្តិធម៌ ប៉ុន្តែព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានភ្លាមនោះទេ ។ ដរាបណាព្រះរាជអាជ្ញាធ្វើការបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម[39]។ ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញាមុនសម្រេចធ្វើការចោទប្រកាន់ ត្រូវពិនិត្យលើកត្តាចំបងមួយចំនួនដូចជា៖

- តើអំពើដែលបានប្រព្រឹត្តនោះមានធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌដែរឬទេ?
- ត្រូវធ្វើការកំណត់ថាអំពើដែលបានប្រព្រឹត្តជាបទល្មើស
- តើជនសង្ស័យមានអភ័យឯកសិទ្ធិដែរឬទេ?
- ជនសង្ស័យដែលត្រូវចោទប្រកាន់ ត្រូវឱ្យសមស្របនឹងអំពើប្រព្រឹត្ត

ក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ បន្ទាប់ពីបានកសាងសំណុំរឿងឡើង ដោយបានធ្វើការស៊ើបអង្កេតយ៉ាងត្រឹមត្រូវរួចមក ព្រះរាជអាជ្ញាបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណាក់កាលចោទប្រកាន់។ ព្រះរាជអាជ្ញាត្រូវសម្រេចថាចំពោះបទល្មើសដែលបានធ្វើការស៊ើបអង្កេតរកឃើញនោះគួរធ្វើការចោទប្រកាន់ដែរឬទេ? ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្តឹងអាជ្ញានៅក្នុងការធ្វើបណ្តឹង បណ្តឹងនេះទៀតសោតត្រូវអនុវត្តលើគ្រប់បុគ្គលទាំងអស់រួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដោយឈរលើគោលការណ៍ឥតប្រកាន់ពូជសាសន៍ ពណ៌សំបុរ ភេទ សាសនា និន្នាការនយោបាយ ឬស្ថានភាពឯទៀតឡើយ។

[39] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ម្យ៉ាងវិញទៀត ក្នុងការធ្វើបណ្តឹងអាជ្ញានេះមានគោលបំណងដើម្បីធ្វើពិនិត្យពីអទិភាពនៃបទល្មើស បង្ហាញឱ្យឃើញពីពិរុទ្ធភាពរបស់ជនល្មើស ធ្វើការផ្តន្ទាទោសតាមច្បាប់ដែលបានកំណត់ និងធានាសណ្តាប់ធ្នាប់សាធារណៈ និងការពារផលប្រយោជន៍ទូទៅ។

ការចោទប្រកាន់របស់ព្រះរាជអាជ្ញាគឺជា ចំណាត់ការនីតិវិធីមួយដែលព្រះរាជអាជ្ញា មានអានុភាព និងសមត្ថកិច្ចពេញលេញទៅលើយុត្តាធិការស៊ើបសួរ និងជំនុំជម្រះ។ ក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញាពីបណ្តឹងអាជ្ញា អាចធ្វើបានលុះត្រាតែអង្គការអយ្យការបានទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ តាមរយៈជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹងមក ឬអ្នកតំណាងរបស់គេ។

ដោយយោងលើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការកំណត់អំពីការចោទប្រកាន់នៃបទល្មើសរបស់ព្រះរាជអាជ្ញាដូចជា៖

**ក. ការបើកការស៊ើបសួរ**

**ខ. ការបញ្ជូនជំនុំជម្រះផ្ទាល់**

**គ. ការបង្ហាញខ្លួនភ្លាម**

## ៣.១. ការចោទប្រកាន់តាមការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាការធ្វើបណ្តឹងរបស់ព្រះរាជអាជ្ញាទៅចៅក្រមស៊ើបសួរ ដើម្បីបើកការស៊ើបសួរមកលើអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ម្យ៉ាងវិញទៀតផ្អែកលើការស្រាវជ្រាវទៅលើអង្គហេតុរបស់ចៅក្រមស៊ើបសួរ គឺមានលក្ខណៈខុសពីការស្រាវជ្រាវដែលបានធ្វើឡើងដោយព្រះរាជអាជ្ញា ដោយមូលហេតុថាព្រះរាជអាជ្ញាធ្វើការស្រាវជ្រាវលើព័ត៌មាន និងភស្តុតាងទាំងឡាយណាដើម្បីធ្វើការកំណត់ឱ្យឃើញពីការពិតអំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌក្នុងការចោទប្រកាន់។ ដោយឡែកសំណុំរឿងដែលត្រូវបានបញ្ជូនឱ្យមកចៅក្រមស៊ើបសួរតាមរយៈដីកាបញ្ជូនរឿងឱ្យស៊ើបសួរធ្វើការស៊ើបសួរនោះ ចៅក្រមស៊ើបសួរត្រូវតែ

បំពេញភារកិច្ចរបស់ខ្លួន ធ្វើការស្រាវជ្រាវ ដើម្បីស្វែងរកឱ្យឃើញពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើស ដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់បន្ថែមពីនេះទៅទៀត ចៅក្រមស៊ើបសួរនឹងត្រូវធ្វើការស្រាវជ្រាវនូវរាល់គ្រប់ទិន្នន័យនៃព័ត៌មានទាំងអស់ដែលរួមមាន ភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក[40]។

### ៣.១.១. លក្ខខណ្ឌ និងទម្រង់ដែលធ្វើឱ្យមានការចំណាត់ការក្នុងការបើកការស៊ើបសួរ

ដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានធ្វើការកំណត់អំពីលក្ខខណ្ឌមួយចំនួនដើម្បីបើកការស៊ើបសួរ ស្របតាមនីតិវិធីក្នុងការចោទប្រកាន់របស់ព្រះរាជអាជ្ញា។ លក្ខខណ្ឌដែលព្រះរាជអាជ្ញាត្រូវគោរពមុនសម្រេចធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបើកការស៊ើបសួរនោះ ត្រូវមើលលើប្រភេទនៃបទល្មើសជាមុនសិន។ ដោយយោងតាមមាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការកំណត់ពីប្រភេទនៃបទល្មើសមុននឹងធ្វើការបើកការស៊ើបសួររួមមាន៖ បទឧក្រិដ្ឋ និងបទមជ្ឈឹម៖

**ករណីបទឧក្រិដ្ឋ៖** កាលណាមានបទល្មើសឧក្រិដ្ឋកើតឡើង ព្រះរាជអាជ្ញាចាំបាច់ត្រូវតែបើកការស៊ើបសួរ[41]។ រាល់គ្រប់បទល្មើសទាំងឡាយណាដែលជាប្រភេទបទឧក្រិដ្ឋត្រូវតែមានបើកការស៊ើបសួរ ដោយមូលហេតុថាបទល្មើសឧក្រិដ្ឋ គឺជាប្រភេទបទល្មើសទាំងឡាយណាដែលមានអប្បបរមានៃទោសក្នុងពន្ធនាគារពី ៥ឆ្នាំទៅ ៣០ឆ្នាំ និងអតិបរមាជាទោសដាក់ពន្ធនាគារអស់មួយជីវិត[42]។

ដោយសារមូលហេតុនៃការកម្រិតទោសទៅលើជនល្មើសមានលក្ខណៈធ្ងន់ធ្ងរ តម្រូវឱ្យមានការធ្វើការស្រាវជ្រាវឱ្យមានល្អិតល្អន់ និងជាក់លាក់ច្បាស់លាស់មុននឹងសម្រេចនាំខ្លួនជនល្មើសទៅធ្វើការជំនុំជម្រះនៅមុខតុលាការ ពីព្រោះចៀសវាងក្នុងការធ្វើការជំនុំជម្រះដោយមាន

[40] មាត្រា ១២៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[41] មាត្រា ៨៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[42] មាត្រា ៨៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧

ការធ្វេសប្រហែស ឬមានការភាន់ច្រលំដែលនាំឱ្យមានប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាព និង សេចក្ដីថ្លៃថ្នូររបស់ជនដែលត្រូវបានចោទប្រកាន់ ម្យ៉ាងវិញទៀតដើម្បីធានាដល់ការអនុវត្តការកាត់ក្ដី ប្រកបដោយយុត្តិធម៌សម្រាប់ភាគីទាំងសងខាង។ បទឧក្រិដ្ឋនេះទៀតសោតត្រូវធ្វើការស៊ើបសួរជាមុន ដែលស្ថិតក្រោមថៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរ ទាំងភស្ដុតាងក្នុងការដាក់បន្ទុក និង ភស្ដុតាងក្នុងការដោះបន្ទុកព្រោះដើម្បីធ្វើការត្រួតពិនិត្យដោយជាក់លាក់ និងស្វែងឱ្យការដឹងពីការពិត ព្រមទាំងបង្ហាញឱ្យច្បាស់លាស់ពីការជំនុំជម្រះរបស់ប្រព័ន្ធយុត្តាធិការប្រកបដោយភាពយុត្តិធម៌។

**ករណីបទមជ្ឈឹម៖** ដោយយោងតាមមាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីបទមជ្ឈឹម ព្រះរាជអាជ្ញាក៏អាចអនុវត្តនីតិវិធីនេះបានដែរ ដោយព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបាន[43]។ ដោយមូលហេតុបទមជ្ឈឹម ជាប្រភេទបទល្មើសមានការដាក់ទោសឱ្យជាប់ពន្ធនាគារមានរយៈពេលលើសពី ៦ ថ្ងៃ និងក្រោម ឬ ស្មើនឹង ៥ ឆ្នាំ និងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[44]។

ការបើកការស៊ើបសួរចំពោះបទមជ្ឈឹម មិនមែនការកំណត់ឱ្យមានច្បាស់អំពីប្រភេទបទមជ្ឈឹមដែលមានលក្ខណៈស្មុគស្មាញយ៉ាងណានោះទេ តែស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌបានផ្ដល់ឆន្ទានុសិទ្ធិ ដល់ព្រះរាជអាជ្ញាក្នុងការសម្រេចដោយធ្វើការពិនិត្យឱ្យច្បាស់អំពីស្ថានភាពនៃបទល្មើស ផ្ទុយទៅវិញប្រសិនបើជនត្រូវចោទបានប្រព្រឹត្តបទល្មើសនោះ តែមិនមានភស្ដុតាងគ្រប់គ្រាន់ ឬមិនស្គាល់ពីអត្តសញ្ញាណរបស់ជនត្រូវចោទនោះ បានសេចក្ដីថាសំណុំរឿងមិនទាន់មានព័ត៌មានគ្រប់គ្រាន់ឬ ឯកសារមិនគ្រប់គ្រាន់ដើម្បីធ្វើការជំនុំជម្រះបាន ដូច្នេះហើយព្រះរាជអាជ្ញានឹងត្រូវធ្វើការចោទប្រកាន់ទៅតាមនីតិវិធីក្នុងការស៊ើបសួរ។

[43] មាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[44] មាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

សរុបសេចក្ដីមក រាល់ស្ថានភាពនៃបទល្មើសទាំងអស់រួមមានបទឧក្រិដ្ឋ ឬបទមជ្ឈឹមដែលបានធ្វើការធ្វើបកស្រាយខាងលើនេះ គឺត្រូវតែចាំបាច់ធ្វើការចោទប្រកាន់ទៅតាមរយៈការបើកការស៊ើបសួរ។

### ៣.១.២. នីតិវិធី និងទម្រង់នៃការបើកការស៊ើបសួរ

ជាក់ស្ដែង នៅក្នុងរឿងក្ដីព្រហ្មទណ្ឌព្រះរាជអាជ្ញាដែលបានទទួលសំណុំរឿងពីការដាក់ពាក្យបណ្ដឹងរបស់ដើមបណ្ដឹងមកព្រះរាជអាជ្ញា ឬតាមរយៈពាក្យបណ្ដឹងដែលបញ្ជូនសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌។ ដូច្នេះព្រះរាជអាជ្ញាមុននឹងសម្រេចបើកការស៊ើបសួរត្រូវធ្វើការវាយតម្លៃ និងវិនិច្ឆ័យឱ្យបានច្បាស់លាស់ទៅលើសំណុំរឿងតាមប្រភពនៃការបញ្ជូននីមួយៗ។

#### ៣.១.២.១. ការបើកការស៊ើបសួរដោយទទួលពាក្យបណ្ដឹងបញ្ជូនមក

ពាក្យបណ្ដឹងអាចធ្វើឡើងដោយផ្ទាល់ពីដើមបណ្ដឹង ដើម្បីឱ្យព្រះរាជអាជ្ញាងាយស្រួលក្នុងការធ្វើចំណាត់ការចំពោះពាក្យបណ្ដឹងទាំងនោះ។ នៅពេលព្រះរាជអាជ្ញាបានទទួលពាក្យបណ្ដឹងដោយផ្ទាល់ហើយ នោះព្រះរាជអាជ្ញានឹងចាប់ផ្ដើមធ្វើចំណាត់ការថ្លឹងថ្លែងក្នុងការសម្រេចធ្វើការចោទប្រកាន់ទៅតាមនីតិវិធីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលអង្គហេតុនោះជាបទល្មើស។ ក្នុងការថ្លឹងថ្លែង និងការស្រាវជ្រាវដែលត្រូវបានធ្វើឡើងតាមរយៈការដាក់ពាក្យសុំទៅមន្ត្រីនគរបាលយុត្តិធម៌ដើម្បីធ្វើការបើកការស៊ើបអង្កេតបឋម ឬការកោះហៅ ដើមបណ្ដឹង ជនសង្ស័យ សាក្សី[45] ដើម្បីធ្វើការសាកសួរ និងស្ដាប់ចម្លើយផ្ទាល់។ នៅពេលដែលបញ្ចប់ការបើកការស៊ើបអង្កេត និងស្រាវជ្រាវរួចហើយ ក្នុងករណីដែលអង្គហេតុនោះជាបទល្មើស និងបានបំពេញទៅតាមលក្ខខណ្ឌនៃការបើកការស៊ើបសួរដូចដែលបានបកស្រាយខាងលើ ព្រះរាជអាជ្ញានឹងសម្រេចធ្វើការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

[45] មាត្រា ១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៣.១.២.២. ការបើកការស៊ើបសួរដោយទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌

ការបើកការស៊ើបសួរក៏ធ្វើទៅបានផងដែរ ក្រោយពីបានទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួលបានពាក្យប្តឹងពីជនរងគ្រោះ ឬអ្នកតំណាងរបស់ជនរងគ្រោះទាមទារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌នឹងធ្វើការបើកការស៊ើបអង្កេតជាបឋមចំពោះរាល់បណ្តឹងដែលមន្ត្រីនគរបាលយុត្តិធម៌បានទទួល ឬពេលដែលមានបទឧក្រិដ្ឋ បទមជ្ឈឹម ឬបទលហុណាមួយ រួចបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ លើសពីនេះទៅទៀតចំពោះករណីដែលមានបទល្មើសជាក់ស្តែងកើតមានឡើង មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិធ្វើការចាប់ខ្លួន ឬឃាត់ខ្លួនទៅលើជនសង្ស័យនឹងបញ្ជូនខ្លួនជនសង្ស័យទៅចំពោះមុខព្រះរាជអាជ្ញា។ ចំពោះនីតិវិធីនៃការអនុវត្តលើចំណាត់ការនៃរឿងក្តី ដែលត្រូវបានបញ្ជូនមកមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើឡើងក្រោមរូបភាពដូចខាងក្រោម៖

- **សំណុំរឿងដែលមានជនសង្ស័យ៖** គឺជាសំណុំរឿងទាំងឡាយណាដែលត្រូវបានចាប់ជនសង្ស័យនោះបាន ឬក៏មានការឃាត់ខ្លួនជនសង្ស័យដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលបាននាំខ្លួនជនសង្ស័យនោះមកអនុវត្តនីតិវិធីនៅចំពោះមុខព្រះរាជអាជ្ញា ក្រោយពេលនៃការឃាត់ខ្លួនត្រូវបានកន្លងផុត ហើយព្រះរាជអាជ្ញាអាចបើកការសាកសួរចម្លើយ និងពិនិត្យទៅលើរាល់សំណុំរឿងទៅលើជនសង្ស័យផងដែរ។ ព្រះរាជអាជ្ញាពិនិត្យទៅលើតែលើអង្គហេតុ និងភស្តុតាងដែលជារបាយការណ៍សំយោគនៃសំណុំរឿងដែលមន្ត្រីនគរបាលយុត្តិធម៌បាន ធ្វើការសន្និដ្ឋានក្រោយពីបានស្តាប់ចម្លើយជនត្រូវចោទ។ ក្នុងករណីនេះប្រសិនបើការពិនិត្យលើសំណុំរឿងឃើញថាជាបទល្មើស និងបានបំពេញលក្ខខណ្ឌក្នុងការបើកការស៊ើបសួរ នាំឱ្យព្រះរាជអាជ្ញានឹងចេញសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បន្ថែមពីនេះព្រះរាជអាជ្ញាអាចធ្វើការសន្និដ្ឋានសុំឱ្យចៅក្រមស៊ើបសួរដាក់ជននោះស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬសន្និដ្ឋានសុំឱ្យជននោះស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្នបានផងដែរ។

– **សំណុំរឿងដែលគ្មានជនសង្ស័យ៖** សំដៅដល់សំណុំរឿងទាំងឡាយណាដែលបានបញ្ជូនមកមន្ត្រីនគរបាលយុត្តិធម៌ដែលជនសង្ស័យពុំត្រូវបានឃាត់ខ្លួន ហើយបញ្ជូនមកកាន់ព្រះរាជអាជ្ញាទេ។ ព្រះរាជអាជ្ញាដែលបានទទួលសំណុំរឿងនេះ នឹងធ្វើការថ្លឹងថ្លែងទៅលើអង្គហេតុ ដោយមានការពិនិត្យយ៉ាងល្អិតល្អន់ទៅលើភស្តុតាង និងរបាយការណ៍សំយោគដែលទទួលបានពីមន្ត្រីនគរបាលយុត្តិធម៌ និងធ្វើការកោះហៅភាគីដែលពាក់ព័ន្ធដូចជា ដើមបណ្តឹង សាក្សី ជនសង្ស័យ ដើម្បីធ្វើការសាកសួរ និងស្តាប់ចម្លើយ។ ក្រោយពីបានធ្វើការសាកសួររួច ក្នុងករណីដែលអង្គហេតុនៃសំណុំរឿងគឺជាបទល្មើសនោះ ហើយបានបំពេញលក្ខខណ្ឌ ដែលតម្រូវឱ្យព្រះរាជអាជ្ញាបើកការស៊ើបសួរ និងចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយកំណត់ឈ្មោះជនត្រូវចោទ ឬអញ្ញាតជន ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

### ៣.១.២.៣. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យធ្វើការស៊ើបសួរ

ក្នុងខណៈពេលដែលមានការសម្រេចពី ការចោទប្រកាន់តាមរយៈការស៊ើបសួរពីព្រះរាជអាជ្ញានោះ តម្រូវឱ្យព្រះរាជអាជ្ញាចាំបាច់ត្រូវធ្វើការរៀបចំលិខិតនីតិវិធី គឺដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យធ្វើការស៊ើបសួរ ទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីបំពេញមុខងាររបស់ខ្លួនក្នុងការស៊ើបសួរ។ ម្យ៉ាងវិញទៀតនោះ ព្រះរាជអាជ្ញាត្រូវបំពេញលិខិតទម្រង់នៃដីកានោះឱ្យបានច្បាស់លាស់ផងដែរ ដោយស្របតាមនីតិវិធីនៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យធ្វើការស៊ើបសួរនោះរួមមាន៖

- សេចក្តីសង្ខេបអង្គហេតុ
- ការកំណត់ឈ្មោះនៃបទល្មើស
- ការបង្ហាញអត្ថបទដែលបានកំណត់ឱ្យបានច្បាស់លាស់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវបានធ្វើការស៊ើបសួរ ក្នុងករណីដែលបានធ្វើការកំណត់រួច។

ក្នុងទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការកំណត់អំពីលក្ខណៈដាច់ខាត ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែគោរព បានសេចក្ដីថាប្រសិនបើចំណុចនៃទម្រង់ការនៃដីកាសន្និដ្ឋាននេះមិនបានបំពេញ នោះនាំឱ្យដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនឹងត្រូវចាត់ទុកជាមោឃៈ[46] ដោយមូលហេតុថា សភាស៊ើបសួរបានទទួលបានពាក្យសុំមោឃភាពពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណី[47] ។

## ៣.១.៣. អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ក្រោយពីបាន សម្រេចធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា បានធ្វើឱ្យដីកានេះបង្កើតឱ្យមានអានុភាពដូចជាការផ្ដាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចដល់ចៅក្រមស៊ើបសួរឱ្យបើកកិច្ចស៊ើបសួរ និងការកំណត់ពីដែនសមត្ថកិច្ចលើការស៊ើបសួរៈ

– **ការកំណត់ដែនសមត្ថកិច្ចលើកការស៊ើបសួរៈ** ក្នុងកិច្ចស៊ើបសួរលើអង្គហេតុដែលបានធ្វើឡើងដោយ ចៅក្រមស៊ើបសួរដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ។ ក្នុងលក្ខខណ្ឌដែលបទល្មើសព្រហ្មទណ្ឌមួយបានលេចចេញឡើងនៅអង្គហេតុថ្មីនោះ ចៅក្រមស៊ើបសួរមានភារកិច្ចត្រូវជូនព័ត៌មានដែលទាក់ទងទៅនឹងអង្គហេតុនេះទៅកាន់ព្រះរាជអាជ្ញា ម្យ៉ាងវញទៀតចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរទៅអង្គហេតុថ្មីដែលខ្លួនបានរកឃើញនោះតាមការស្នើសុំរបស់ព្រះរាជអាជ្ញា តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[48] កិច្ចស៊ើបសួរអាចត្រូវមោឃភាពបានក្នុងករណីដែលកិច្ចស៊ើបសួរនេះត្រូវបានបំពានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញា។ ម្យ៉ាងវិញទៀត មានករណីខ្លះមិនចាំបាច់មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ ដូចជាប្រសិនបើមានអង្គហេតុថ្មីបានរក

[46] មាត្រា ៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[47] មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[48] មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ឃើញហើយមានស្ថានទម្ងន់ទោសទៀតនោះ តែត្រូវបានកំណត់ជាស្រេចក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

– **ការផ្ដាច់រយៈពេលនៃអាជ្ញាយុកាលនៃបទល្មើស៖** ចិរវេលានៃអាជ្ញាយុកាលរបស់បទល្មើស គឺត្រូវគិតចាប់ផ្ដើមពីដែលបានប្រព្រឹត្តបទល្មើស។ ការចោទប្រកាន់ ឬការបើកការស៊ើបសួរបាននាំឱ្យមានការផ្ដាច់អាជ្ញាយុកាល[49] បានសេចក្ដីថាគ្រប់កិច្ចចោទប្រកាន់ទាំងអស់ពីសំណាក់ព្រះរាជអាជ្ញា ទោះជាតាមរយៈការបង្ហាញខ្លួនភ្លាម ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬការបើកការស៊ើបសួរនោះទេ ព្រោះសញ្ញាណនៃការចោទប្រកាន់មួយដែលនាំឱ្យមានការផ្ដាច់អាជ្ញាយុកាលនៃបទល្មើស។ ចំពោះគ្រប់កិច្ចនៃការស៊ើបសួរ សំដៅទៅរាល់កិច្ចដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំពោះមុខចៅក្រមស៊ើបសួរ កិច្ចទាំងនេះក៏មានអានុភាពកាត់ផ្ដាច់អាជ្ញាយុកាលនៃបណ្ដឹងផងដែរ។

– **ការផ្ទេរសមត្ថកិច្ចទៅកាន់ចៅក្រមស៊ើបសួរដើម្បីឱ្យធ្វើការស៊ើបសួរ៖** គ្មានកិច្ចចោទប្រកាន់ណាពីសំណាក់ព្រះរាជអាជ្ញាទេ ប្រសិនបើគ្មានការធ្វើការស៊ើបសួរជាមុននោះតែលើកលែងតែការដាក់ឱ្យមានចលនាបណ្ដឹងអាជ្ញាដោយជនរងគ្រោះ។ កិច្ចស៊ើបសួរនឹងត្រូវមោឃភាព បើសិនជាគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ការប្ដឹងមោឃភាព គឺជាសកម្មភាពទាំងឡាយដែលបានប្ដឹងទៅកាន់សភាស៊ើបសួរ ក្នុងករណីដែលយល់ឃើញខុសនីតិវិធីកិច្ចស៊ើបសួរ។

## ៣.២. ការចោទប្រកាន់តាមការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ដើម្បីចាប់ផ្ដើមនីតិវិធីក្នុងកិច្ចបញ្ជូនរឿងឱ្យជំនុំជម្រះផ្ទាល់បាន លុះត្រាតែព្រះរាជអាជ្ញាសម្រេចចេញដីកាមួយជាមុនសិន ដែលយើងហៅថា **ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**[50]។

ការចោទប្រកាន់តាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីដែលព្រះរាជអាជ្ញាបញ្ជាឱ្យជនជាប់ចោទ ដើម្បីធ្វើការចូលមកបង្ហាញខ្លួននៅចំពោះមុខសាលាជម្រះក្ដីជាន់ទាប

[49] មាត្រា១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[50] មាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

(តុលាការដំបូង)[51] ។ នីតិវិធីជំនុំជម្រះផ្ទាល់នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានធ្វើការកំណត់នូវលក្ខខណ្ឌចំបងមួយចំនួន ហើយក៏មានការកំណត់នូវគោលបំណងដើម្បីធានាសិទ្ធិរបស់ជនល្មើសក្នុងកិច្ចជំនុំជម្រះតាមរយៈតុលាការដោយធ្វើការចោទប្រកាន់ជនល្មើស និងបញ្ជូនសំណុំរឿងមកធ្វើការជំនុំជម្រះតែម្តងដោយមិនចាំបាច់ឆ្លងកាត់ទៅតាមនីតិវិធីព្រហ្មទណ្ឌឡើយ។ កិច្ចដំណើរការជំនុំជម្រះផ្ទាល់នេះ គឺទាមទារឱ្យមានលក្ខណៈឆាប់រហ័ស ដោយសារការចោទប្រកាន់នេះបានផ្ទេរពីអង្គការអយ្យការមកកាន់ចៅក្រមស៊ើបសួរដើម្បីធ្វើការជំនុំជម្រះ។ ចំពោះកិច្ចដំណើរការនីតិវិធីជំនុំជម្រះផ្ទាល់នេះ ត្រូវទាមទារគោរពលក្ខខណ្ឌមួយចំនួនផងដែរ ដើម្បីធ្វើឱ្យដីកានេះមានអានុភាពដល់ចំណាត់ការរបស់យុត្តាធិការជំនុំជម្រះផងដែរ។

### ៣.២.១. លក្ខខណ្ឌដែលនាំឱ្យមានការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

នៅពេលដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ ដោយប្រើនីតិវិធីនៃការបញ្ជូនរឿងទៅឱ្យជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាចាំបាច់ត្រូវតែចេញដីកាកោះហៅបញ្ជូនរឿងជំនុំជម្រះផ្ទាល់ ដែលដីកានេះទាមទារឱ្យគោរពទៅតាមលក្ខខណ្ឌមួយចំនួន ។ លក្ខខណ្ឌនេះ គឺសំដៅទៅលើលក្ខខណ្ឌនៃបទល្មើសរបស់ជនល្មើសត្រូវបានបំពេញ និងលក្ខណៈនៃសារជាតិរបស់ជនល្មើសដែលបានបំពេញៈ

#### ៣.២.១.១ លក្ខខណ្ឌនៃបទល្មើស

ចំពោះលក្ខខណ្ឌនៃបទល្មើសត្រូវកំណត់ទៅតាមប្រភេទនៃបទល្មើសព្រហ្មទណ្ឌ ដែលមានការបែងចែកជា៣ ធំៗ គឺ បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ[52]។ ម្យ៉ាងវិញទៀត ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានធ្វើការបកស្រាយព្រមទាំងបង្ហាញពីធាតុផ្សំនៃបទល្មើសបទលហុ និងបទមជ្ឈិម ដែលបានផ្តល់អំណាចឱ្យព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់ដោយប្រើប្រាស់នីតិវិធីបញ្ជូនរឿឱ្យជំនុំជម្រះផ្ទាល់។

---

[51] មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧

[52] មាត្រា ៤៥ និងមាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ក. លក្ខខណ្ឌចំពោះបទលហុ

បទលហុគឺសំដៅទៅលើបទល្មើសទាំងឡាយណា ដែលត្រូវបានទទួលទោសដាក់ពន្ធនាគាររយៈពេលអតិបរមានៃទោស ស្មើឬមិនលើសពី៦ថ្ងៃ ឬទោសពិន័យជាប្រាក់តែប៉ុណ្ណោះ[53]។ នៅពេលអង្គហេតុដែលមានស្ថានទោសជាបទលហុនោះ នាំឱ្យព្រះរាជអាជ្ញានឹងសម្រេចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តង ដោយមូលហេតុថាលហុជាប្រភេទបទល្មើសដែលមានលក្ខណៈក្នុងការផ្តន្ទាទោសស្រាល និងតូចតាច។ ផ្ទុយទៅវិញបើត្រូវរងចោទប្រកាន់ដោយប្រើនីតិវិធីផ្សេងៗ ដូចជា ការចូលបង្ហាញខ្លួនភ្លាម ឬ ការបើកការស៊ើបសួរ នាំឱ្យមានការប៉ះពាល់ដល់សិទ្ធិសេរីភាពយ៉ាងធ្ងន់ធ្ងរដល់ជនជាប់ចោទ ព្រោះតាមនីតិវិធីចូលបង្ហាញខ្លួន និងការបើកស៊ើបសួរទាមទារឱ្យមានការឃុំខ្លួនជនជាប់ចោទរហូតដល់បង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។

### ខ. លក្ខខណ្ឌចំពោះបទមជ្ឈិម

បទមជ្ឈិម ជាប្រភេទបទល្មើសមានការដាក់ទោសឱ្យជាប់ពន្ធនាគារមានរយៈពេលលើសពី ៦ ថ្ងៃ និងក្រោម ឬ ស្មើនឹង ៥ ឆ្នាំនិងអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[54]។ ម្យ៉ាងវិញទៀតដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ពុំបានធ្វើការបញ្ជាក់ពីច្បាស់ពីប្រភេទមជ្ឈឹមបែបណា ដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញាធ្វើការជំនុំជម្រះផ្ទាល់បាន ទោះបីជាបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែងក៏ដោយ ព្រោះគេបានផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាជាអ្នកថ្លឹងថ្លែងក្នុងការសម្រេចលើស្ថានភាពនៃអង្គហេតុបទល្មើស។ ម្យ៉ាងវិញទៀត ក្នុងករណីដែលព្រះរាជអាជ្ញាបានពិនិត្យឃើញថាមានភស្តុតាងគ្រប់គ្រាន់ នាំឱ្យតុលាការនឹងធ្វើការជំនុំជម្រះសម្រេចសេចក្តីលើបទល្មើសបាន ដោយព្រះរាជអាជ្ញានឹងប្រើនីតិវិធីក្នុងការចោទប្រកាន់នេះ។ លើសពីនេះទៅទៀតក្នុងការចោទប្រកាន់បទល្មើសជាប្រភេទបទមជ្ឈឹមនេះដែលមានភស្តុតាងគ្រប់គ្រាន់ហើយ ក៏អាចធ្វើការបើកស៊ើបសួរ ឬការចូលបង្ហាញខ្លួនបានផងដែរ ដោយមូលហេតុថាមានករណីបទមជ្ឈឹមមួយ

[53] មាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[54] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ចំនួនតម្រូវឱ្យមានធ្វើការចោទប្រកាន់តាមនីតិវិធីផ្សេងៗបានផងដែរ។ ជាក់ស្តែង ប្រសិនបើមានករណីស្ថានភាពមជ្ឈឹមដែលភាពស្មុគស្មាញក្នុងការដោះស្រាយនោះ តម្រូវឱ្យទាមទារមានការបើកការស៊ើបអង្កេតដើម្បីស្វែងរកភស្តុតាងឱ្យបានគ្រប់គ្រាន់ និងជាក់លាក់ស្របតាមនីតិវិធី។

#### ៣.២.១.២. លក្ខណៈនៃសាវជាតិរបស់ជនល្មើស

ក្រៅពីការកំណត់ប្រភេទនៃបទល្មើសចប់សព្វគ្រប់ហើយ កត្តាចំបងនោះគឺព្រះរាជអាជ្ញាចាំបាច់ត្រូវរកឱ្យឃើញពីសាវជាតិរបស់ជនល្មើសនោះ ព្រោះថាវាជាមូលហេតុចាំបាច់សម្រាប់ធ្វើការកំណត់បង្ហាញពីលក្ខខណ្ឌមួយក្នុងការធ្វើបណ្ដឹងអាជ្ញា ហើយដែលមានគោលបំនងក្នុងការស្វែងរកអត្ថិភាពនៃបទល្មើស បូករួមទាំងការផ្តន្ទាទោសទៅលើជនល្មើសផងដែរ។ នីតិវិធីនៃការបញ្ជូនរឿងឱ្យជំនុំជម្រះផ្ទាល់នេះ ចាំបាច់ធ្វើការទាមទារកំណត់ពីអត្តសញ្ញាណរបស់ជនល្មើសដោយខានមិនបាន ព្រោះថាប្រសិនបើជនល្មើសមិនបានស្ថិតក្នុងភាពស្គាល់អត្តសញ្ញាណទេនោះ នាំឱ្យដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់មិនអាចប្រព្រឹត្តបានទេ។ ម្យ៉ាងវិញទៀត ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌបានធ្វើការទទួលស្គាល់វិសាលភាពនៃបណ្ដឹងចំពោះជនជាប់ចោទ បានសេចក្តីថាតុលាការនឹងធ្វើការជំនុំជម្រះទៅលើជនទាំងឡាយណា ដែលមានក្នុងពាក្យបណ្ដឹងតែប៉ុណ្ណោះ។ ដូច្នេះការស្គាល់នូវអត្តសញ្ញាណរបស់ជនល្មើសគឺជាកត្តាចាំបាច់ និងជាលក្ខខណ្ឌដែលមិនអាចខ្វះបានឡើយ។

### ៣.២.២. នីតិវិធី និងទម្រង់នៃដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់

នីតិវិធីនៃការបញ្ជូនរឿងជំនុំជម្រះផ្ទាល់ គឺសំដៅទៅលើនីតិវិធីមួយដែលមិនចាំបាច់ធ្វើការឆ្លងកាត់នូវដំណាក់កាលស៊ើបសួរនោះទេ ដែលជាហេតុនាំឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ភ្លាមតាមរយៈពាក្យបណ្ដឹង និងលក្ខខណ្ឌនៃការបញ្ជូនរឿងជំនុំជម្រះផ្ទាល់ បន្ទាប់មកក៏បញ្ជូនសំណុំរឿងនេះតាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់ទៅកាន់យុត្តាធិការដើម្បីធ្វើការជំនុំជម្រះផ្ទាល់ និងចេញដីកាកោះហៅជនជាប់ចោទចូលមកសវនាការធ្វើការជំនុំជម្រះ។ ម្យ៉ាងវិញទៀត ការចោទប្រកាន់តាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះផ្ទាល់នេះ ព្រះរាជអាជ្ញាចាំបាច់ត្រូវតែបំពេញលក្ខខណ្ឌឱ្យស្រប

តាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដែលបានបង្ហាញ ក្នុងគោលបំណងធានាឱ្យបានដីកាកោះហៅមានសុពលភាព។

ព្រះរាជអាជ្ញានឹងអនុវត្តដីកាកោះហៅបញ្ជូនមកទៅជំនុំជម្រះផ្ទាល់ឡើង ដោយមានទម្រង់ច្បាស់លាស់ និងជាក់លាក់ដើម្បីងាយស្រួលដល់ចៅក្រមជំនុំជម្រះពិនិត្យ និងវិនិច្ឆ័យថាបទល្មើសដែលចៅក្រមធ្វើការចោទប្រកាន់នោះត្រឹមត្រូវតាមនីតិវិធីច្បាប់។ ម្យ៉ាងទៀតដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ មាត្រា ៤៦ បានធ្វើការកំណត់ពីទម្រង់នៃដីកាកោះហៅជំនុំជម្រះផ្ទាល់ ដែលជាមូលហេតុនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រមទាំងកំណត់នូវផលប្រយោជន៍ដ៏សំខាន់ក្នុងកិច្ចជំនុំជម្រះ ហើយទម្រង់នៃដីកាកោះហៅជំនុំជម្រះផ្ទាល់រួមមាន៖

- អត្តសញ្ញាណរបស់ជនជាប់ចោទ
- សេចក្តីសង្ខេបរបស់អង្គហេតុ
- ឈ្មោះបទល្មើស
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

សរុបសេចក្តីមក ក្រៅពីទម្រង់នៃដីកាកោះហៅជំនុំជម្រផ្ទាល់ដែលបានធ្វើការបកស្រាយខាងលើនេះ ព្រះរាជអាជ្ញាក៏អាចចេញដីកាចង្អុលប្រាប់ពីតុលាការ ទីកន្លែងចោទប្រកាន់ កាលបរិច្ឆេទ និងម៉ោងនៃការបើកសវនាការផងដែរ ព្រោះថាការជូនដំណឹងនេះតាមដីកានេះ មានភាពងាយស្រួលដោយមិនចាំបាច់ចេញដីកាកោះហៅឱ្យចូលសវនាការទេ[55]។

### ៣.២.៣. លក្ខខណ្ឌដែលនាំឱ្យមានសុពលភាពលើដីកាកោះហៅជំនុំជម្រះផ្ទាល់

តាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ក្នុងការធានាជនជាប់ចោទ តម្រូវឱ្យមានរយៈពេលសមស្របដើម្បីឱ្យជនជាប់ចោទបានត្រៀមលក្ខណៈឡើងសវនាការ។ ម្យ៉ាងវិញទៀត ការកំណត់

[55] មាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នេះមានរយៈពេលខុសៗគ្នាដែលវាអាស្រ័យទៅលើស្ថានភាពទីតាំង ដែលជនជាប់ចោទមានវត្តមាន។ ដោយយោងតាមមាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានធ្វើការកំណត់រយៈពេលនៃការចេញដីកាកោះហៅជនជាប់ចោទដូចតទៅៈ

- ១៥ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង
- ២០ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ
- ២ ខែ ប្រសិនបើជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា
- ៣ ខែ ប្រសិនបើជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

ក្នុងករណីដែលលក្ខខណ្ឌដែលទាក់ទងទៅនឹងរយៈពេលនេះត្រូវបានគោរពនោះ ដីកាកោះហៅជំនុំជម្រះផ្ទាល់ និងដីកាបង្ហាញខ្លួនភ្លាមនឹងមិនត្រូវអនុវត្តឡើយ ឬអាចធ្វើឡើងដោយបំពាននោះ តុលាការយល់ឃើញថាដីកានោះមានអានុភាពធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនជាប់ចោទនាំឱ្យតុលាការប្រកាសនូវមោឃភាពនៃដីកាកោះហៅជំនុំជម្រះផ្ទាល់នោះតែម្តង។

### ៣.២.៤. អានុភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ នាំឱ្យមានការបង្កើតនូវអានុភាពមួយចំនួនមានជាអាទ៍ ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ច និងដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ។

– **ការផ្តាច់អាជ្ញាយុកាលនៃបទល្មើសៈ** ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏ជានីតិវិធីនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដែលជាហេតុនាំឱ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ហើយចាប់ផ្តើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល។ ប្រសិនបើគ្មានការកំណត់បែបនេះទេ អាចមានករណីខ្លះនៅពេលដែលបណ្តឹងបញ្ជូនទៅតុលាការ តែត្រូវផុតអាជ្ញាយុកាលដែលនាំឱ្យជនល្មើសត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនទៅវិញ។

– **ការផ្ទេរសមត្ថកិច្ចទៅតុលាការ៖** ខុសពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរឱ្យបើកកិច្ចស៊ើបសួរ តែដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ត្រូវបានប្រគល់សំណុំរឿងទៅឱ្យតុលាការធ្វើការជំនុំជម្រះតែម្តង ដោយពុំឆ្លងកាត់ដំណាក់កាលចៅក្រមស៊ើបសួរឡើយ។

– **ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងជនជាប់ចោទ៖** តុលាការនឹងធ្វើការជំនុំជម្រះតែទៅលើអង្គហេតុ និងបុគ្គលដែលបានកំណត់ក្នុងកំណត់ហេតុស្តីអំពីការបង្គាប់ឱ្យមានបង្ហាញខ្លួនតែប៉ុណ្ណោះ។ តុលាការពុំអាចធ្វើការជំនុំជម្រះទៅលើអង្គហេតុ និងបុគ្គលផ្សេងដែលពុំមានកំណត់ក្នុងកំណត់ហេតុនោះឡើយ។

## ៣.៣. ចោទប្រកាន់តាមរយៈកំណត់ហេតុបង្ហាញខ្លួនភ្លាម

ការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម ជានីតិវិធីមួយក្នុងចំណោមនីតិវិធីទាំងបីនៃការចោទប្រកាន់ខាងបទព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញា ដែលអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមនៅចំពោះមុខតុលាការជាន់ដំបូង។ នីតិវិធីនេះ បញ្ញត្តិឡើងដើម្បីជម្រុញដល់ដំណើរការរឿងក្តីឱ្យបានរហ័សជៀសវាងការកកស្ទះ ប៉ុន្តែទោះជាយ៉ាងណាការអនុវត្តនូវការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមត្រូវតែគោរពនូវលក្ខខណ្ឌ នីតិវិធីដែលត្រូវអនុវត្ត ក៏ដូចជាការបង្កើតឱ្យមានអានុភាពផងដែរ។

### ៣.៣.១. លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម

ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នោះព្រះរាជអាជ្ញាអាចធ្វើការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមនៅមុខតុលាការ មានជាអាទិ៍៖

– បទល្មើសជាបទមជ្ឈិមជាក់ស្តែង៖ បើពិនិត្យមើលមាត្រា ៨៧ ដដែល ត្រង់ចំណុចទី ១ នេះច្បាប់ប្រើពាក្យថា បទល្មើសជាបទល្មើសជាក់ស្តែង ហើយបានចង្អុលបង្ហាញទៅមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) និង មាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង) ប៉ុន្តែនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមអនុវត្តបានតែចំពោះបទល្មើសដែលជាបទមជ្ឈិម

ជាក់ស្តែងតែប៉ុណ្ណោះ ព្រោះនឹងមានបង្ហាញនូវក្នុងចំណុចទី ២បន្ទាប់ ដែលបានកំណត់ពីការផ្តន្ទាទោសដាក់ពន្ធនាគារ។ ដូចនេះ បទល្មើសជាបទឧក្រិដ្ឋជាក់ស្តែងក៏ដោយ ឬ បទមជ្ឈិមមិនជាក់ស្តែងក៏ដោយ ព្រះរាជអាជ្ញាពុំអាចអនុវត្តតាមនីតិវិធីនេះបានទេ។

– បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ (មួយ) ឆ្នាំ និងយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ៖ ជាការបង្ហាញឱ្យឃើញកាន់តែច្បាប់ថាបទល្មើសត្រូវតែជាបទមជ្ឈិម ដែលការផ្តន្ទាទោសជាអប្បបរមា ១ (មួយ) ឆ្នាំ និងអតិបរមា ៥ (ប្រាំ) ឆ្នាំ។

– ជនជាប់ចោទជានីតិជន៖ មានន័យថាការដែលជនជាប់ចោទត្រូវដល់នីតិភាព ដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ។ ការកំណត់បែបនេះដើម្បីជៀសវាងការប៉ះពាល់ដល់សិទ្ធិរបស់អនីតិជន ដោយហេតុថានីតិវិធីនេះមានការជំនុំជម្រះលឿន ហើយបើពុំបានកំណត់ជនជាប់ចោទជានីតិជនទេ នាំឱ្យមានការប៉ះពាល់ទៅដល់សិទ្ធិការពារខ្លួនរបស់អនីតិជននោះ។

– រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន៖ ព្រះរាជអាជ្ញាត្រូវតែមានភស្តុតាង ឬមូលហេតុធន់ល្មមក្នុងការដាក់បន្ទុកដើម្បីធ្វើការចោទប្រកាន់ ព្រោះបើគ្មានភស្តុតាង ឬហេតុផលដ៏រឹងមាំក្នុងការដាក់បន្ទុកជនល្មើសនាំឱ្យតុលាការសម្រេចឱ្យរួចខ្លួន ជាហេតុនាំឱ្យព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់ជាថ្មីបានដោយសារគោលការណ៍អាជ្ញាអស់ជំនុំ។

### ៣.៣.២. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

នីតិវិធីនៃការបង្ហាញខ្លួនភ្លាម គឺជានីតិវិធីមួយដែលមានលក្ខណៈខុសប្លែកពីនីតិវិធីទាំងពីរខាងលើ ដោយហេតុថានីតិវិធីនេះមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់។ យោងតាមបញ្ញត្តិនៃមាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចកំណត់បានពីនីតិវិធីនៃការបង្ហាញខ្លួនភ្លាមជាពីរដំណាក់កាលគឺ នីតិវិធីក្នុងដំណាក់កាល់ព្រះរាជអាជ្ញា និងនីតិវិធីក្នុងដំណាក់កាលយុត្តាធិការជំនុំជម្រះ៖

#### ក. នីតិវិធីក្នុងដំណាក់កាលព្រះរាជអាជ្ញា

បន្ទាប់ពីបានពិនិត្យមើលអង្គហេតុដែលជាពាក្យប្តឹង ឬពាក្យបរិហារដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធមិបញ្ជូនមក បើត្រូវជ្រើសរើសនីតិវិធីនៃការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម នោះព្រះរាជអាជ្ញាត្រូវ៖

- ពិនិត្យអត្តសញ្ញាណបុគ្គលដែលត្រូវបញ្ជូនមក
- ឱ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវដែលត្រូវចោទប្រកាន់ និងបទល្មើស
- ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ
- ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ទម្រង់ការខាងលើត្រូវតែចុះក្នុងកំណត់ហេតុ បើមិនដូច្នោះទេត្រូវចាត់ទុកថាមោឃៈ។ ក្រោយពីធ្វើកំណត់ហេតុរួចហើយ ជនជាប់ចោទត្រូវបង្ខាំងទុកដោយកងកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅ ចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅក្នុងថ្ងៃនោះតែម្តង។

### ខ. នីតិវិធីក្នុងដំណាក់កាលយុត្តាធិការជំនុំជម្រះ

នៅពេលដែលទទួលបានកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម តុលាការត្រូវធ្វើការផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានចោទប្រកាន់នោះ ហើយត្រូវប្រាប់ដល់ជនជាប់ចោទពីរយៈពេលសម្រាប់រៀបចំដើម្បីការពារខ្លួន។

បើជនជាប់ចោទយល់ថាខ្លួនពុំទាន់មានពេលគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន អាចធ្វើការសុំរយៈពេលបន្ថែម ឬក្នុងករណីដែលតុលាការយល់ឃើញថាអង្គហេតុនោះនៅមិនទាន់អាចជំនុំជម្រះបាន តុលាការអាចលើកសវនាការនៅពេលក្រោយបាន។ ក្នុងករណីនេះ តុលាការអាចធ្វើការបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ដោយចេញសាលក្រមមានបញ្ជាក់ពីសំអាងហេតុដែលជាមូលហេតុចាំបាច់នៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មានជាអាទិ៍៖

- ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឱ្យកើតជាថ្មី

- ដើម្បីរារាំងកុំឱ្យមានការគាប់សង្កត់លើសាក្សី ឬ ជនរងគ្រោះ ឬ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។

ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គ្រាន់តែមានអានុភាពទៅលើជនជាប់ចោទប៉ុណ្ណោះ ជាហេតុនាំឱ្យតុលាការត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដើម្បីធ្វើការបញ្ជាឱ្យដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទ[56]។

គិតចាប់ពីថ្ងៃចូលទៅបង្ហាញខ្លួននៅមុខតុលាការ តុលាការត្រូវប្រកាសសាលក្រមលើអង្គសេចក្តីក្នុងរយៈពេល ដែលមិនអាចលើសពី ២ (ពីរ) សប្តាហ៍។ បើពុំនោះទេ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយពេញច្បាប់ ហើយជនជាប់ចោទត្រូវដោះលែងឱ្យមានសេរីភាពឡើងវិញ ព្រោះវិធានការនៃការឃុំខ្លួនបណ្តោះអាសន្ន ជាការប៉ះពាល់យ៉ាងខ្លាំងដល់សេរីភាពរបស់បុគ្គលដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។

### ៣.៣.៣. អានុភាពនៃការបង្ហាញខ្លួនភ្លាម

ប្រសិនបើព្រះរាជអាជ្ញាធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម នោះអានុភាពនឹងកើតឡើងតាមកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមដូចជា ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ការផ្ទេរសមត្ថកិច្ចទៅតុលាការ និងការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងបុគ្គល។

[56] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

– **ការផ្តាច់អាជ្ញាយុកាលនៃបទល្មើស៖** អាជ្ញាយុកាលត្រូវផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់ ចំពោះកំណត់ហេតុស្តីពីអំពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមក៏ជាកិច្ចនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញាដែរ ដែលមានអានុភាពនាំឱ្យមានការផ្តាច់អាជ្ញាយុកាលនៃបទល្មើស ហើយចាប់ផ្តើមគិតថិរវេលាថ្មីនៃអាជ្ញាយុកាល។

– **ការផ្ទេរសមត្ថកិច្ចទៅតុលាការ៖** ផ្ទេរមកយុត្តាធិការជំនុំជម្រះតែម្តង ដោយពុំឆ្លងកាត់យុត្តាធិការស៊ើបសួរឡើយ។

– **ការកំណត់ដែនសមត្ថកិច្ចចំពោះអង្គហេតុ និងបុគ្គល៖** តុលាការនឹងធ្វើការជំនុំជម្រះតែទៅលើអង្គហេតុ និងបុគ្គលដែលបានកំណត់ក្នុងកំណត់ហេតុស្តីអំពីការបង្គាប់ឱ្យមានបង្ហាញខ្លួនតែប៉ុណ្ណោះ។ តុលាការពុំអាចធ្វើការជំនុំជម្រះទៅលើអង្គហេតុ និងបុគ្គលផ្សេងដែលពុំមានកំណត់ក្នុងកំណត់ហេតុនោះឡើយ៕

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមការបកស្រាយប្រធានបទសារណាខាងលើ យើងអាចសន្និដ្ឋានបានថាអង្គការអយ្យការអមសាលាដំបូង បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងលំហូរនីតិវិធីនៃការចោទប្រកាន់ខាងបទព្រហ្មទណ្ឌ។ ហើយយើងក៏អាចសង្កេតឃើញយ៉ាងច្បាស់ពីតួនាទីរបស់អង្គការអយ្យការដែលត្រូវបានផ្តល់សិទ្ធិតាមរយៈរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ និងជាពិសេសមានចែងក្នុងច្បាប់នីតិវិធី។

អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ហើយការចោទប្រកាន់នេះទៀតសោធច្បាប់នៃប្រទេសកម្ពុជាយើង បានប្រកាន់យកនូវគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដែលព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់នូវរាល់បទល្មើសដែលកើតមានឡើង មិនថាអំពើនោះបង្កព្យសនកម្មដល់សណ្តាប់ធ្នាប់សាធារណៈមានកម្រិតធ្ងន់ធ្ងរ ឬតិចតួចយ៉ាងណាក៏ដោយ។ ការកំណត់យកគោលការណ៍នេះដើម្បីបញ្ឈប់រាល់បទល្មើសកុំឱ្យកើតមានឡើង ប៉ុន្តែវាហាក់ដូចជាព្រៃផ្សៃ ចំពោះទង្វើដែលមានកម្រិតគ្រោះថ្នាក់តិចតួចហើយធ្វើការចោទប្រកាន់ លើសពីនេះទៅទៀតវាក៏កើតមាននូវផលវិបាកយ៉ាងច្រើនផងដែរនៅក្នុងសង្គម។ ហេតុនេះហើយ បានជាកម្ពុជាធ្វើការផ្លាស់ប្តូរទៅតាមបរិបទសង្គមដោយងាកមកយកគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញ។ មានន័យថាព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើគួរចោទប្រកាន់ ឬយ៉ាងណាចំពោះអំពើដែលបង្កើតជាបទល្មើស។ គោលការណ៍នេះផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន ក្នុងការជួយសម្រួលដល់ដំណើរការរឿងក្តីក្នុងតុលាការ ឱ្យបានឆាប់រហ័សដើម្បីជៀសវាងការកក់ស្ទះសំណុំរឿង។ បន្ថែមពីលើនេះទៅទៀតវាក៏ជួយសម្រួលដល់រាល់បទល្មើសណាដែលមានចរិតគ្រោះថ្នាក់តូចតាច ព្រោះថាការចោទប្រកាន់ពីបទល្មើសណាមួយដើម្បីធ្វើការផ្តន្ទាទោសជនល្មើស ក្នុងគោលបំណងធ្វើការអប់រំ និងកែប្រែជនល្មើសនោះ ឱ្យត្រលប់មករស់នៅក្នុងស្ថានភាពដែលសង្គមទទួលស្គាល់វិញប៉ុណ្ណោះ

មិនមែនជាការសងសឹកទេ។ ដូចនេះវាហាក់ដូចជាគ្មានប្រយោជន៍អ្វីទាល់តែសោះក្នុងការចោទប្រកាន់ចំពោះអំពើដែលព្រះរាជអាជ្ញា យល់ឃើញថាអាចលើកលែងបាន។ ទន្ទឹមនឹងនេះ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ក៏កើតមានជាវិបាកផងដែរ ដែលអាចនាំឱ្យបទល្មើសដែលមានកម្រិតគ្រោះថ្នាក់តូចតាចនោះកើតមានឡើងក្នុងសង្គមឥតឈប់ឈរជាអាទិ៍។

សរុបសេចក្តីមក ជម្រើសនៃការចោទប្រកាន់របស់អង្គការអយ្យការតាមរយៈការប្រកាន់យកនូវគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់នេះបានដើរតួយ៉ាងសំខាន់ក្នុងការផ្តល់ឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ ឬ សម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះបទល្មើសព្រហ្មទណ្ឌ។ អង្គការអយ្យការជាភាពដែលមិនអាចខ្វះបាន គឺចាំបាច់បំផុតក្នុងដំណើរការនៃនីតិវិធីក្នុងរឿងក្តីព្រហ្មទណ្ឌផលដែរ បើគ្មានការចូលរួមក្នុងការចោទប្រកាន់ពីសំណាក់ព្រះរាជអាជ្ញា ក៏ពុំកើតមាននូវកិច្ចស៊ើបសួរ ក៏ដូចជាកិច្ចជំនុំជម្រះផងដែរ៕

# អនុសាសន៍

# អនុសាសន៍

អង្គការអយ្យការ គឺជាស្ថាប័នមួយដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យមានតម្លាភាព និងប្រកបដោយភាពយុត្តិធម៌ តែរាល់សកម្មភាពទាំងនេះតម្រូវឱ្យមានៈ

១. ធ្វើការអប់រំ បណ្តុះបណ្តាលចំណេះដឹងនៅក្រមនីតិវិធីព្រហ្មទណ្ឌ ទៅដល់មន្ត្រីទាំងឡាយឱ្យមានចំណេះដឹងទូលំទូលាយក្នុងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព និងត្រឹមត្រូវទៅតាមច្បាប់កំណត់ដែលមានចែងក្នុងក្រមនេះ។ ជាពិសេស គឺផ្តល់នូវពុទ្ធិដល់មន្ត្រីដែលបានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចដំណើរការក្នុងរឿងក្តីព្រហ្មទណ្ឌឱ្យបានដឹងពីតួនាទី និងភារកិច្ចរបស់ពួកគាត់ឱ្យបានប្រសើរ ដូចដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់មក។ ម្យ៉ាងវិញទៀត ការអបរំ ការផ្សព្វផ្សាយបណ្តុះបណ្តាលក្នុងគោលបំណងជៀសវាងកុំមានវិវាទសមត្ថកិច្ចក្នុងកិច្ចដំណើរការរឿងក្តីព្រហ្មទណ្ឌ។

២. ធ្វើការបង្កើនធនធានមនុស្សដែលមានចំណេះជំនាញលើប្រព័ន្ធយុត្តិធម៌ដូចជា ចៅក្រមព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌ បន្ថែមតាមរយៈការប្រឡងជ្រើសរើស និងបណ្តុះបណ្តាលប្រកបដោយវិជ្ជាជីវៈ ព្រោះថាដើម្បីជួយសម្រួលដល់កិច្ចជំនុំជម្រះរឿងក្តីដែលមានភាពយឺតយ៉ាវដោយសារការខ្វះខាតនៅធនធានមនុស្សដែលមានវិជ្ជាជីវៈក្នុងការអនុវត្តលើកិច្ចដំណើររឿងក្តីព្រហ្មទណ្ឌនេះ។

៣. ដើម្បីលើកទឹកចិត្តដល់មន្ត្រីដែលមានតួនាទី និងភារកិច្ចក្នុងប្រព័ន្ធយុត្តិធម៌ តាមការរយៈការតំឡើងប្រាក់បៀវត្ស ឱ្យបានសមរម្យដោយគិតពីជីវភាពរស់នៅសព្វថ្ងៃរបស់ពួកគាត់ ឬសេវាថែទាំសុខភាព និងសេវាផ្សេងៗទៀតដែលជាប្រយោជន៍សម្រាប់ពួកគាត ដើម្បីចៀសវាងកុំឱ្យមានសកម្មភាពអំពើពុករលួយកើតមានឡើងក្នុងប្រព័ន្ធតុលាការដោយសារ តែកង្វះខាតការយកចិត្តពី

រាជរដ្ឋាភិបាល និងការមិនផ្តល់ប្រាក់បៀវត្សគ្រប់គ្រាន់ ហើយវាក៏បញ្ហាមួយដែលប៉ះពាល់ដល់ប្រព័ន្ធយុត្តិធម៌ ជាពិសេសគឺយុត្តិធម៌របស់ប្រជាជនក្រីក្រ។

៤. ត្រូវពិនិត្យឡើងវិញឱ្យមានល្អិតល្អន់ពីតួនាទី ភារកិច្ចរបស់អង្គការអយ្យការថា តើកិច្ចដំណើររបស់អង្គការអយ្យការ បានដំណើរការដូចនឹងអ្វីដែលស្របទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌដែរឬទេ? ហើយថាតើរវាងស្ថាប័នអយ្យការ និងស្ថាប័នផ្សេងៗមានដំណើរទៅយ៉ាងរលូនដោយមិនមានវិវាទសមត្ថកិច្ចដែនដីនឹងគ្នានោះ។

៥. បង្កើតឱ្យមានអង្គការ ឬស្ថាប័នក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃចំពោះប្រព័ន្ធយុត្តិធម៌ ថាតើលំហូរនីតិវិធី ឬ ការជំនុំជម្រះប្រព្រឹត្តទៅដោយភាពត្រឹមត្រូវឬទេ?

# ឯកសារយោង

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្តជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

៣. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៤. ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

៥. ច្បាប់ស្តីពី លក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

៦. ច្បាប់ស្តីពី ឯកពន្ធភាព ឆ្នាំ២០០៦

៧. ច្បាប់ស្តីពី ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥

## II. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

១. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨

២. កតិកាសញ្ញាស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ឆ្នាំ១៩៦៦

៣. គោលការណ៍ណែនាំស្តីពី តួនាទីព្រះរាជអាជ្ញា ឆ្នាំ១៩៩០

## III. សៀវភៅ

១. មេរៀនស្តីពី នីតិវិធីព្រហ្មទណ្ឌ និងព្រហ្មទណ្ឌពិសេសដោយសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១៦

២. មេរៀនស្ដីពី នីតិព្រហ្មទណ្ឌទូទៅ ដោយសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងលោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១២

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១៖**

- ដីកាឆែកឆេរលំនៅដ្ឋាន

**ឧបសម្ព័ន្ធទី ២៖**

- ដីកាតម្កល់រឿងទុកឥតចាត់ការ

**ឧបសម្ព័ន្ធទី ៣៖**

- ដីកាសម្រេចបំបែកសំណុំរឿង

**ឧបសម្ព័ន្ធទី ៤៖**

- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

**ឧបសម្ព័ន្ធទី ៥៖**

- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

**ឧបសម្ព័ន្ធទី ៦៖**

- ដីកាចាត់ឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម

**ឧបសម្ព័ន្ធទី ៧៖**

- ដីកាសន្និដ្ឋានស្ថាពរ

**ឧបសម្ព័ន្ធទី ៨៖**

- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

**ឧបសម្ព័ន្ធទី ៩៖**

- ដីកាកោះ

**ឧបសម្ព័ន្ធទី ១០៖**

- ដីកាបញ្ជាឱ្យចូលខ្លួន

**ឧបសម្ព័ន្ធទី ១១៖**

- កំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

**ឧបសម្ព័ន្ធទី ១២៖**

- ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្ន

**ឧបសម្ព័ន្ធទី ១៣៖**

- ដីកាបង្គាប់ឱ្យឃុំខ្លួន

**ឧបសម្ព័ន្ធទី ១៤៖**

- ដីកាបង្គាប់ឱ្យចាប់ខ្លួន

**ឧបសម្ព័ន្ធទី ១៥៖**

- ដីកាបង្គាប់ឱ្យដោះលែង

**ឧបសម្ព័ន្ធទី ១៦៖**

- ដីកាបង្គាប់ឱ្យឈប់ចាប់ខ្លួន

**ឧបសម្ព័ន្ធទី ១៧៖**

- ដីកាសម្រេច

**ឧបសម្ព័ន្ធទី ១៨៖**

- ដីកាផ្ទេរសមត្ថកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
ដំបូងរាជធានីភ្នំពេញ
................ អ.យ

## ដីកាឆែកឆេរលំនៅដ្ឋាន

**យើង ................... តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

-បានឃើញ ..........................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

### យល់ឃើញថា :

ដើម្បីរុករកវត្ថុតាង និងបង្ក្រាបបទល្មើសទាក់ទិនករណីខាងលើ ..........................................

..........................................................................................................................

.......................................................................... ធ្វើការឆែកឆេរលំនៅដ្ឋានខាងលើ ។

### ហេតុដូច្នេះសំរេច :

-ឆែកឆេរលំនៅដ្ឋានផ្ទះលេខ .............. ផ្លូវ ............ ភូមិ ...................... សង្កាត់ .................... ខណ្ឌ .................... រាជធានីភ្នំពេញ។

រាជធានីភ្នំពេញ ; ថ្ងៃទី ......... ខែ .......... ឆ្នាំ

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

លេខ : .................. អ.យ

## ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង .................. តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងលេខ .................. ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ .......... របស់អយ្យការអមសាលាដំបូង រាជធានីភ្នំពេញ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងកស្តុតាងនានា។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា :

១. អវត្តមានបទល្មើស

១.១. ☐ អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☐ ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

៣.១. ☐ ការដកពាក្យបណ្តឹង

៣.២. ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☐ មរណភាពជនល្មើស

៣.៤. ☐ ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្រុះសម្រួលជាមួយរដ្ឋ

៣.៨. ☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្រុះសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយ័តភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

៤. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

៤.១. ☐ ការស្វែងរកមិនបានផល

៤.២. ☐ ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

៤.៣. ☐ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

---

[1] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2] [illegible]

៤.៤. ☐ ការខកខានរបស់ដើមបណ្តឹង

៤.៥. ☐ អាកប្បកិរិយារបស់ជនរងគ្រោះ

៤.៦. ☐ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

៤.៧. ☐ និយ័តកម្មដោយឯកឯង[៣]

៤.៨. ☐ ព្យសនកម្ម ឬ ការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. ☐ ការជួសជុលការខូចខាតដោយ / ដល់អនីតិជន

៥.២. ☐ សន្ទានកម្ម[៤]

៥.៣. ☐ អធិបញ្ញាផ្តល់ការព្យាបាល

៥.៤. ☐ ជនរងគ្រោះ / ដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. ☐ និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

៥.៦. ☐ ការរំលឹកពីអត្ថបទច្បាប់ / ការព្រមាន[៥]

៥.៧. ☐ ការកំណត់ទិសដៅចំពោះចេតនាសម្ពន្ធ័នៃសុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. ☐ ការសម្រុះសម្រួលព្រហ្មទណ្ឌ[៦]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. ☐ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១. ☐ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១. ☐ ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

ការសង្កេតផ្សេងៗ :

---

[៣] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[៤] ករណីចែងដោយច្បាប់

[៥] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានឱ្យឈប់ប្រព្រឹត្ត

[៦] ករណីចែងដោយច្បាប់

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ .......... ឆ្នាំ

តំណាងអយ្យការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

សាលាដំបូងរាជធានីភ្នំពេញ

លេខ : .................... អ.យ

## ដីកាសម្រេចបំបែកសំណុំរឿង

**យើង .................... តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាម ព្រះរាជក្រឹត្យលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

**យល់ឃើញថា**

-ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ អង្គហេតុនៃរឿងបង្ហាញថា : កាលពីថ្ងៃទី .......... ខែ .......... ឆ្នាំ ជនត្រូវចោទឈ្មោះ .................... ភេទ .......... អាយុ .......... ឆ្នាំ និងឈ្មោះ .................... ត្រូវជាប់ចោទពីបទ ....................

ប្រព្រឹត្តនៅ ....................

កាលពីថ្ងៃទី .......... ខែ .......... ឆ្នាំ ។ ហើយនៅ ថ្ងៃទី .......... ខែ .......... ឆ្នាំ ជនត្រូវចោទឈ្មោះ .................... ភេទ .......... អាយុ .......... ឆ្នាំ ត្រូវជាប់ចោទ ពីបទ ....................

ប្រព្រឹត្តនៅ ....................

កាលពីថ្ងៃទី .......... ខែ .......... ឆ្នាំ ជាអង្គហេតុពីរផ្សេងគ្នា ថ្ងៃប្រព្រឹត្តខុសគ្នា ។

-តាមអង្គហេតុនៃរឿង ដូចបានរៀបរាប់ខាងលើ

-គប្បីបំបែកសំណុំរឿងព្រហ្មទណ្ឌថ្មីលើឈ្មោះ .................... ភេទ .......... អាយុ .......... ឆ្នាំ ចេញពីសំណុំរឿងព្រហ្មទណ្ឌលេខ .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ

**ហេតុដូច្នេះសម្រេច**

១-បំបែកសំណុំរឿងព្រហ្មទណ្ឌលេខ .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ លើឈ្មោះ .................... ភេទ .......... អាយុ .......... ឆ្នាំ ចេញពីសំណុំរឿងព្រហ្មទណ្ឌលេខ .................... ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ .. ជាសំណុំរឿងដោយឡែកពីគ្នា ហើយចុះយកលេខ សំណុំរឿងថ្មី ។

២-បង្គាប់មកលោកក្រឡាបញ្ជី ចាត់ចែងបំពេញបែបបទ ដើម្បីបំបែកសំណុំរឿងនេះ ដោយចុះយកលេខសំណុំរឿងថ្មី ឱ្យបានត្រឹមត្រូវ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

រាជធានីភ្នំពេញ , ថ្ងៃទី .......... ខែ .......... ឆ្នាំ

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ..............
ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ ..........
លេខ : ........................ អ.យ

# <u>ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ</u>

យើង ........................ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញសំណុំរឿងលេខ ........................ ចុះថ្ងៃទី .............. ខែ .............. ឆ្នាំ ..............

របស់[1] ........................................................................................................................ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា មានតម្រុយសន្ទត់បានថា :

១- នាម-គោត្តនាម ________________ ហៅ ____________ ភេទ ☐ប្រុស-☐ស្រី អាយុ ______ ឆ្នាំ

ជាតិ ____________ របររកស៊ី ________________________________

ទីកន្លែងកំណើត __________ ឃុំ-សង្កាត់ __________ ស្រុក-ខណ្ឌ __________ ខេត្ត-ក្រុង __________

ទីលំនៅបច្ចុប្បន្ន ________________________________________

ទោសពីមុន ________ ឪពុកឈ្មោះ ____________ "☐រ-☐ស" ម្ដាយឈ្មោះ ____________ "☐រ-☐ស"

ប្ដី ឬ ប្រពន្ធឈ្មោះ ____________ "☐រ-☐ស" មានកូន ________ ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

២- នាម-គោត្តនាម ________________ ហៅ ____________ ភេទ ☐ប្រុស-☐ស្រី អាយុ ______ ឆ្នាំ

ជាតិ ____________ របររកស៊ី ________________________________

ទីកន្លែងកំណើត __________ ឃុំ-សង្កាត់ __________ ស្រុក-ខណ្ឌ __________ ខេត្ត-ក្រុង __________

ទីលំនៅបច្ចុប្បន្ន ________________________________________

ទោសពីមុន ________ ឪពុកឈ្មោះ ____________ "☐រ-☐ស" ម្ដាយឈ្មោះ ____________ "☐រ-☐ស"

ប្ដី ឬ ប្រពន្ធឈ្មោះ ____________ "☐រ-☐ស" មានកូន ________ ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

បានប្រព្រឹត្តអំពើដូចតទៅ[2] :

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

........................................................................................................................

---

[1] លេខសំណុំរឿងរបស់អង្គភាពនគរបាលយុត្តិធម៌

[2] សេចក្ដីសង្ខេបអង្គហេតុ

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

អំពើខាងលើជាបទល្មើស ..................................................................................................

ប្រព្រឹត្តនៅ ..................................................................................................................

កាលពីថ្ងៃទី .............. ខែ .............. ឆ្នាំ .............. តាមបញ្ញត្តិមាត្រា ..........................................

នៃច្បាប់ ..................................................................................................................។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## សម្រេច

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង :

☐ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ[៣] : ..........................................................................

..................................................................................................................................

..................................................................................................................................

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៤] : ...............................................

..................................................................................................................................

..................................................................................................................................

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន[៥] : .......................................................

..................................................................................................................................

..................................................................................................................................

រាជធានីភ្នំពេញ , ថ្ងៃទី ......... ខែ .......... ឆ្នាំ

**តំណាងអយ្យការ**

---

[៣] ឈ្មោះជនត្រូវចោទ

[៤] កាតព្វកិច្ចណាមួយដែលមានចែងនៅក្នុងមាត្រា ២២៣

[៥] មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលមានចែងនៅក្នុងមាត្រា ២០៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

យ្យការអម

ូងរាជធានីភ្នំពេញ

ព្រហ្មទណ្ឌលេខ ..............

...... ខែ ......... ឆ្នាំ ...........

.......................... អ.យ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

**យើង ........................ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញនីតិវិធីស៊ើបសួរលើឈ្មោះ ........................................................ ជាជនត្រូវចោទ

ពីបទ ..........................................................................[២] ។

យល់ឃើញថា អង្គហេតុ :

☐ ដែលត្រូវបានចៅក្រមស៊ើបសួររកឃើញ ហើយបានបញ្ជូនមកអោយយើង តាមដីកាបញ្ជូនយើងឆ្លើយ ចុះថ្ងៃទី ............ ខែ ............ ឆ្នាំ ............ ។

☐ ដែលត្រូវបានដឹងតាមសំណុំលិខិតនីតិវិធីដែលមានភ្ជាប់មកជាមួយ[៣] ជាអង្គហេតុថ្មី ដែលមិនមានចង្អុលបង្ហាញនៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ .................... ចុះថ្ងៃទី ............ ខែ ............ ឆ្នាំ ............ ។

យល់ឃើញថា យោងតាមអង្គហេតុថ្មីនេះ មានតម្រុយសន្មត់ថា :

១- នាម-គោត្តនាម ................................ ហៅ ...................... ភេទ ☐ប្រុស-☐ស្រី អាយុ ......... ឆ្នាំ

ជាតិ ........................ របររកស៊ី ..........................................................................

ទីកន្លែងកំណើត .................. ឃុំ-សង្កាត់ ................ ស្រុក-ខណ្ឌ ................ ខេត្ត-ក្រុង ................

ទីលំនៅបច្ចុប្បន្ន ..........................................................................................

ទោសពីមុន ............ ឪពុកឈ្មោះ .................... "☐រ-☐ស" ម្តាយឈ្មោះ .................... "☐រ-☐ស"

ប្តី ឬ ប្រពន្ធឈ្មោះ .................... "☐រ-☐ស" មានកូន ............ ឬ ☐នៅលីវ - ☐អនីតិជន ឬ ☐នីតិជន ។

បានប្រព្រឹត្តអំពើ ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា .............. នៃច្បាប់ ..............................

.......................................................................................................... ។

បានឃើញមាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

---

[១] លេខសំណុំរឿងអយ្យការ ដែលចៅក្រមស៊ើបសួរកំពុងស៊ើបសួរ

[២] ឈ្មោះបទល្មើស

[៣] ព័ត៌មានអំពីអង្គហេតុថ្មីពាក់ព័ន្ធនឹងជនត្រូវចោទ ដែលអយ្យការដឹងតាមរយៈបណ្តឹងរបស់ពលរដ្ឋ ឬ សំណុំរឿងរបស់នគរបាលយុត្តិធម៌ (ករណីនេះ អយ្យការមិនត្រូវចុះលេខសំណុំរឿងថ្មីទេ)

## សម្រេច

បើកការស៊ើបសួរបន្ថែមចំពោះករណីនេះ តាមនីតិវិធីនៃច្បាប់ នឹងស្នើសុំឱ្យ :

☐ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ[៤] : ..............................................................

..............................................................

..............................................................

☐ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៥] : ..............................................................

..............................................................

..............................................................

☐ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន[៦] : ..............................................................

..............................................................

..............................................................

រាជធានីភ្នំពេញ , ថ្ងៃទី .......... ខែ .......... ឆ្នាំ

**តំណាងអយ្យការ**

---

[៤] ឈ្មោះជនត្រូវចោទ

[៥] កាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា ២២៣

[៦] មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលបានចែងនៅក្នុងមាត្រា ២០៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

យ្យការអម

ូងរាជធានីភ្នំពេញ

ព្រហ្មទណ្ឌលេខ..........

.... ខែ........ ឆ្នាំ..........

.................... អ.យ

## ដីកាសន្និដ្ឋានស្ថាពរ

**យើង ........................ តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ........................ ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ .......... ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ .............. ចុះថ្ងៃទី ....... ខែ ....... ឆ្នាំ ........ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបញ្ជូនឱ្យឆ្លើយដើម្បីបញ្ចប់ការស៊ើបសួរលេខ .................... ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ ........ ។

-បានឃើញដីបញ្ជូនរឿងទៅពិនិត្យលេខ .................... ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ ........ របស់ចៅក្រមស៊ើបសួរ ។

### ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញថា :

១. នាម-គោត្តនាម ........................................ ហៅ ........................ ភេទ ☐ប្រុស-☐ស្រី អាយុ ........ ឆ្នាំ

